ព្រឹត្តិប័ត្រ មរតកខ្មែរ

Morodok Khmer

លេខ ០៥ ឆ្នាំទី ០១ ខែកក្កដា គ.ស. ២០១០ - ព.ស. ២៥៥៤

# ពុទ្ធបរិស័ទកំពុងរាប់បាត្រព្រះសង្ឃ វត្តខេមររង្សី ក្រុងសាន់ហូសេ



## អំពីប្រវត្តិបុណ្យចូលវស្សា និងទំនៀមទម្លាប់ព្រះពុទ្ធសាសនា

មាតិការឿង ទំព័រ


- មនុស្សចិត្តខ្វាក់.............................០៤
- កិរិយាបរិច្ចាគទាន..........................០៧
- ការជួបសំណេះសំណាលជាមួយ....០៨
- ប្រវត្តិសង្ខេបបុណ្យឯករាជ្យជាតិ......០៩
- ទូន្មានចិត្តខ្លួនឯងបាន ទើបនៅ.........១២
- ឧបករណ៍ទ្រខ្មែរ...........................១៣
- ខ្មែរក្រោម១៧គ្រួសារ.....................១៨
- ស្ត្រី១០រូបក្លាយជាសេដ្ឋីនី................១៩
- តុលាការដាក់កំហិតឱ្យ..................២៣
- ជំនួបកំពូល G8.............................២៤
- ខ្ទឹមមានគុណប្រយោជន៍.................២៥


ដោយយោងទៅតាមប្រពៃណីទំនៀមទម្លាប់ នៃព្រះពុទ្ធសាសនា លុះចូលដល់រដូវវស្សាហើយ ពុទ្ធបរិស័ទដែលរស់នៅជុំវិញពិភពលោក ជាអ្នកគោរពប្រតិបត្តិឪវាទព្រះពុទ្ធនោះ តែងតែនាំគ្នីគ្នារៀបចំប្រារព្ធពិធី **បុណ្យចូលវស្សា** នៅគ្រប់វត្តអារាមទាំងអស់។

បុណ្យនេះទៀតសោត គឺជាបុណ្យមួយមានប្រភពកើតមកតាំងអំពីអតីតកាលម្ល៉េះ គ្រាដែលព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង និងពួកភិក្ខុសង្ឃទាំង១២៥០អង្គ បានសំរេចព្រះទ័យផ្លាស់ប្តូរពីចំការត្នោតមកគង់នៅក្នុងព្រៃឫស្សីទៀបក្រុងរាជគ្រឹះ ដោយសារនៅក្នុងរដូវវស្សាមានការលំបាកនៃការសាងសង់វត្តថ្មីនិងដល់ការនិមន្តបិណ្ឌបាតផង។ នៅគ្រានោះដែរមានពួកភិក្ខុមួយចំនួនបានចូលទៅគាល់ព្រះសាស្តាចារ្យ ថាបពិត្រព្រះអង្គដ៏ចំរើន! ពេលដែលខ្ញុំព្រះករុណានិមន្តទៅ *(តទៅទំព័រទី៦)*

**វត្តខេមររង្សី ក្រុងសាន់ហូសេ**
1594 Cunningham Ave San Jose, CA 95122
Tel: (408) 923-2166 / 550-5060
http://www.unitedkhmerkrom.org

# លិខិតអញ្ជើញ បុណ្យចូលវស្សា

យើងខ្ញុំ ជាគណៈកម្មការ អាចារ្យ និងពុទ្ធបរិស័ទ ចំណុះជើង **វត្តខេមររង្សី** ក្រុងសាន់ហូសេ រដ្ឋកាលីហ្វ័រញ៉ា បានមូលមតិគ្នា ប្រារព្ធបុណ្យ **ចូលវស្សា** ដែលជាប្រពៃណី ទំនៀមទម្លាប់ ព្រះពុទ្ធសាសនា គឺបវារណាព្រះសង្ឃ ចូលកាន់វស្សា រយៈពេល៣ខែ នាថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១០ នៅវត្តខេមររង្សី ក្រុងសាន់ហូសេ។

អាស្រ័យដូចបានជំរាបជូនខាងលើ យើងខ្ញុំ សូមគោរពអញ្ជើញ លោក លោកស្រី និងពុទ្ធបរិស័ទជិតឆ្ងាយ មេត្តាចូលរួមញ៉ាំងពិធីបុណ្យចូលវស្សានេះ ឲ្យបានច្រើនកុះករ និងជាវទៀនវស្សា ដើម្បីវេរប្រគេនព្រះសង្ឃ ទុកជាពន្លឺបញ្ញាសម្រាប់បច្ចុប្បន្ន និងទៅអនាគតជាតិ រួចអនុមោទនានូវបុណ្យកុសលនោះរៀងៗខ្លួនកុំបីខានឡើយ។

## *កម្មវិធីបុណ្យ*

## ថ្ងៃអាទិត្យ ទី ២៥ ខែកក្កដា ឆ្នាំ២០១០ (Sunday July. 25, 2010)

-ពីម៉ោង 9:00AM- 12:00PM ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ ធ្វើពិធីនមស្សការ, សមាទានសីល, រាប់បាត្រ, វេរទៀនវស្សា និងភត្តប្រគេនព្រះសង្ឃ និងជារបង្សុកូល ជាកិច្ចបង្ហើយបុណ្យ។

-ទីកន្លែង៖ វត្តខេមររង្សី 1594 Cunningham Ave. San Jose, CA 95122.

*អ្នកផ្តើមបុណ្យ*

*គណៈកម្មការ និងអាចារ្យវត្ត*



ព្រះសង្ឃ និងពុទ្ធបរិស័ទ វត្តខេមររង្សី ទីក្រុងសាន់ហូសេ កំពុងគោរពប្រតិបត្តិ ព្រះសារីកធាតុ នៃព្រះសម្មាសម្ពុទ្ធ

# មូលហេតុ
## ស្តីពីការចេញផ្សាយ នៃព្រឹត្តិប័ត្រ មត៌កខ្មែរ

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** នៃពុទ្ធិកសមាគមខ្មែរក្រោម វត្តខេមររង្សី នៅទីក្រុងសាន់ហូសេ្ស នឹងចេញផ្សាយតាមគេហទំព័រ http://www.unitedkhmerkrom.org / http://morodokkhmer2010.wordpress.com និងបោះពុម្ពផ្សាយជារៀងរាល់ខែ ដើម្បីពង្រឹងពង្រីក វិស័យវប្បធម៌, ប្រពៃណី, ទំនៀមទម្លាប់, ភាសា, អក្សរសាស្ត្រជាតិ និងដំណឹងថ្មីៗ ពីសហគមន៍ខ្មែរ នៅក្នុងនិងក្រៅប្រទេស។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** ផ្សព្វផ្សាយនូវសកម្មភាពសង្គម, ព័ត៌មានខ្មែរ-អន្តរជាតិ, អប់រំ, សុខភាព, កីឡា, រឿងរ៉ាវប្លែកៗ, សីលធម៌, ទស្សនៈកវី និងពុទ្ធសាសនាជាដើម....។ល។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** យកប្រាសាទព្រះវិហារធ្វើជាសញ្ញា (Logo) ដោយប្រាសាទព្រះវិហារ គឺជាទ្រព្យសម្បត្តិរបស់ជាតិខ្មែរ ហើយអង្គការយូនីស្កូ បានចុះក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក កាលពីថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០០៨ នៅទីក្រុងកេប៊ិច ប្រទេសកាណាដា។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** ចេញផ្សាយជារៀងរាល់ខែ តាមគេហទំព័រ និងបោះពុម្ពចែកចាយដោយឥតគិតថ្លៃ ចាប់ពីថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១០ នេះតទៅ។

សេចក្តីដូចបានប្រគេន-ជំរាបជូនដំណឹងខាងលើ សូមមិត្តអ្នកអាននៅក្នុងនិងក្រៅប្រទេស ជាពិសេសសហគមន៍ខ្មែរ នៅទីក្រុងសាន់ហូសេ្ស មេត្តាជ្រាបជាព័ត៌មាន និងគាំទ្រនូវដំណឹងថ្មីៗ ពីព្រឹត្តិប័ត្រ **មត៌កខ្មែរ** ដោយសោមនស្សរីករាយ។

*បញ្ជាក់៖ លោក លោកស្រី ចង់ផ្សាយពាណិជ្ជកម្មជាមួយ ព្រឹត្តិប័ត្រ មត៌កខ្មែរ សូមទំនាក់ទំនង* Tel: **(408) 923-2166**

ធ្វើនៅទីក្រុងសាន់ហូសេ្ស, ថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១០

គណៈកម្មការ **ព្រឹត្តិប័ត្រ មត៌កខ្មែរ**

## ព្រឹត្តិប័ត្រមត៌កខ្មែរ

- ព្រះតេគុណ សឹង យ៉ឹង រតនា នាយកការផ្សាយ
- ព្រះតេជគុណ ថាច់ សុរិយា និពន្ធនាយក
- លោក អ៊ុក សុភ័ព្វ សម្រួលអត្ថបទ
- អ្នកស្រី គីលីន វិនីតា ពាណិជ្ជកម្ម
- លោក កោះ ថុន ពិនិត្យអត្ថបទ
- អ្នកស្រី បៃ សុផានី ផ្សព្វផ្សាយ
- លោក នឹង ស៊ិន ទីប្រឹក្សា

## អាសយដ្ឋានទំនាក់ទំនង

**ព្រឹត្តិប័ត្រ មត៌កខ្មែរ**
**MORODOK KHMER**
1594 Cunningham Ave.
San Jose, CA 95122. U.S.A
E-mail: morodokkhmer2010@gmail.com
Tel: (408) 923-2166/890-8877/550-5050
http://www.unitedkhmerkrom.org

# មនុស្សចិត្តខ្វាក់

មនុស្សយើងគ្រប់រូប កាលបើនៅមានកិលេស រមែងសុទ្ធសឹងតែនៅមានចំណុចខ្វះខាត នៅក្នុងខន្ធសន្តានគ្រប់ៗគ្នាទាំងអស់ មិនមានអ្នកណាម្នាក់អាចគេចផុត និងបរិសុទ្ធផូរផង់គ្រប់បែបយ៉ាងរកកន្លែងតិះដៀលពីអ្នកដទៃមិនបាននោះឡើយ។

ព្រះសម្មាសម្ពុទ្ធបានទូន្មានសព្វសត្វទាំងអស់ ឲ្យបានយល់ថា កាលបើមានចិត្តស្រឡាញ់រាប់អាននិងសេពគប់ជាមួយបុគ្គលណាហើយ យើងត្រូវសិក្សានិងសម្លឹងមើលនូវបុគ្គលិកលក្ខណៈល្អៗ របស់គេឲ្យបានច្រើនប្រកបដោយភាពស្មោះត្រង់ ចំណែកចំណុចខ្វះខាតវិញបើមានកំហុសតែបន្តិចបន្តួចនោះ យើងត្រូវរំលងចោល ហើយចាប់យកតែចំណុចណា ដែលចំរើនដល់សង្គមជាតិវាប្រសើរជាង ដូច្នេះហើយរមែងធ្វើឲ្យលុបបំបាត់នូវផលអវិជ្ជារបស់ពួកគេ ឬសាបរលាបទៅបន្តិចម្តងៗ នឹងមិនប្រាកដឡើងនូវការទាស់ទែងចិត្តគំនិត ការច្រណែន ការស្អប់ ឬមានចិត្តគំនុំគុំគួនក្នុងអារម្មណ៍យើងឡើយ។

តាមពិតទៅ មនុស្សគ្រប់ៗរូប តែងតែមាននូវលក្ខណៈល្អៗបើយើងមើលដោយចិត្តសប្បុរស មនុស្សណា ដែលមានចិត្តប្រកបដោយព្រហ្មវិហារធម៌ក្នុងខ្លួន រមែងមើលឃើញសេចក្តីល្អ និងគុណសម្បត្តិរបស់អ្នកដទៃបានដោយងាយ។ ចំណែកថ្នាក់ដឹកនាំដែលមិនមានចិត្តធម៌ ឬខ្វះខាតយុត្តិធម៌ក្នុងសង្គម សូម្បីយើងខិតខំប្រឹងប្រែងបំពេញការងារជូនសង្គមឬខំធ្វើនូវសេចក្តីល្អធំធេងប្រាកដឡើង ប៉ុនភ្នំព្រះសុមេរុនៅចំពោះមុខក៏មេដឹកនាំនោះមើលមិនឃើញដែរ។ព្រោះពួកគេមើលឃើញតែប្រយោជន៍ខ្លួនធំជាងអ្វីៗទាំងអស់ ទោះបីអ្នកនៅក្រោមឱវាទមានបញ្ហាលំបាកយ៉ាងណាក្តី ក៏មេដឹកនាំប្រភេទនេះ មិនរវល់និងមិនចាប់អារម្មណ៍ឡើយ ចាំតែ ទទួលផលប៉ុណ្ណោះ បុគ្គលបែបនេះហៅថា មនុស្សមានចិត្តលោភលន់។

មនុស្សមានចិត្តខ្វាក់ ទោះបីមានបុណ្យសក្តិ ឬទ្រព្យសម្បត្តិច្រើនយ៉ាងណាក្តី ក៏មិនដែលយកចិត្តទុកដាក់នឹងអ្នកដទៃទេគិតតែសង្គមគ្រួសាររបស់ខ្លួន ព្រោះមានខ្មោចអគតិទាំង៤ គឺការលំអៀងព្រោះសេចក្តីស្រឡាញ់១ ព្រោះស្អប់១ ព្រោះល្ងង់១ និងព្រោះសេចក្តីភ័យខ្លាច១ វាស្ថិតនៅក្នុងខន្ធសន្តានរបស់គេជានិច្ច។ ដូច្នេះហើយរកអំពើល្អ និងសច្ចធម៌ពីមនុស្សចិត្តខ្វាក់បានលំបាក សូម្បីខ្លួនគេផ្ទាល់ក៏មិនដឹងថា ខ្លួនឯងមានចិត្តយ៉ាងណាដែរ។ ពីព្រោះមួយថ្ងៃៗគិតតែពីផលចំណេញ មិនបានគិតពីភាពក្រីក្រ និងការលំបាកនៃអ្នកទន់ខ្សោយឡើយ។ ដូចពាក្យបុរាណមួយឃ្លាពោលថា *«ការស្រឡាញ់រាប់អាន ឬសេពគប់ជាមនុស្សខ្វាក់ភ្នែកល្អជាជាងសេពគប់ជាមួយមនុស្សមានចិត្តខ្វាក់»*។

សារជាតិរបស់មនុស្សចិត្តខ្វាក់ ច្រើនតែយកពេលវេលាសង្គមជាតិ ធ្វើជំនួញសម្រាប់បំពេញផលប្រយោជន៍ខ្លួនឯងក្នុងការជញ្ជក់ឈាមពីប្រជាពលរដ្ឋស្លូតត្រង់ ជាពិសេសចូលចិត្តកេងប្រវ័ញ្ចពលកម្មពីអ្នកនៅក្រោមបង្គាប់បញ្ជា នឹងពោរពេញទៅដោយកលល្បិចបោកប្រាស់គេ បើនិយាយពីពាក្យសម្តីវិញផ្អែមជាងទឹកឃ្មុំទៅទៀត តែចិត្តខ្មៅដូចបិសាចនិងពិសពុល ច្រើនតែឈ្លានពាន ឬប្លន់យកការងារអ្នកដទៃធ្វើជាត្រីវិស័យក្នុងការបង្ហាញសាច់ដុំ និងឥទ្ធិពលរបស់ខ្លួនឲ្យសាធារជនឃើញថា ខ្លួនមានអំណាច ខ្លួនយកចិត្តទុកដាក់ពីកិច្ចការប្រទេសជាតិ។

យោងតាមទ្រឹស្តីព្រះពុទ្ធសាសនាវិញ បុគ្គលប្រភេទនេះ មិនសូវខ្លាចបាប និង ខ្មាសបាបទេ ដោយសំអាងទៅលើខ្លួនមានទ្រព្យ មានអំណាច និងកើតក្នុងត្រកូលស្តុកស្តម្ភ គេមានកិត្តិយស មានសេចក្តីថ្លៃថ្នូររួចស្រេចទៅហើយ ដោយមិនបាន ត្រួតពិនិត្យពីទង្វើកម្មរបស់ខ្លួនឡើយ មើលងាយអ្នកតូចតាចសាងតែអំពើថោកទាប ដែលសង្គមស្អប់ខ្ពើម.... *(តទៅទំព័រទី១០)*




# ហាងខ្មែរលក់មាស ឡាក់គី

# LUCKY JEWELRY

- មានលក់ពេជ្រ HRD, GIA, IGI គ្រប់មូដ
- មាសសន្លឹក 24K 999, Canada Credit Swiss
- គ្រឿងត្បូង South - Sea Pearl គ្រប់ជំពូក
- មានគ្រឿងអលង្ការនាំចូលថ្មីៗពីបរទេស
- មានរចនាមូដល្អៗទាន់សម័យនិយម
- ទិញចូលមានតម្លៃខ្ពស់
- លក់ចេញមានតម្លៃថោកសមរម្យ
- សូមអញ្ជើញអតិថិជនចូលជាវដោយមេត្រីភាព



• There are vast choices of models for HRD, GIA, IGI diamonds.
* 24K ... 999 flat-carded gold's are available from Canada Credit Swiss.
* All kind availabilities for gems and pearls from South-Sea Pearl.
* Newly imported jewelries from international countries.
* Modernize models are always updated.
* We buy your jewelries with high value offerings.
* We sell our jewelries with low, affordable pricing.
* **Please stop by, and we will guarantee your satisfaction**!

- **ម៉ោងធ្វើការៈ** Mon - Fri: 10:00am - 7:00pm
  Tel: (408) 238-2098

- **2471 Alvin Ave. San Jose, CA 95121**
  មានទទួល Visa, Master Card ៣ខែមិនគិតថ្លៃចុងការ

---

# មជ្ឈមណ្ឌលខ្មែរថែរក្សាភ្នែក SUNRISE

## Sunrise Medical-Dental Center

•មានវេជ្ជបណ្ឌិតស្ទាត់ជំនាញក្នុងការពិនិត្យភ្នែក។
•មានម៉ាស៊ីនទំនើបអាចវាស់ភ្នែកនិងកាត់កញ្ចក់វ៉ែនតា តាមតំរូវការ។
•មានវេជ្ជបណ្ឌិតនិយាយភាសាខ្មែរយ៉ាងស្ទាត់ជំនាញ។







Phone: (408) 227-6444
Fax: (408) 227-5056
www.kasod.com

DR. KENNETH A. WIENER
DR. STEVEN M. KAS
*Optometrists*

Eye Care/Lasik Consultations

Sunrise Medical-Dental Center
5710 Cahalan Avenue, Bldg. 2 San Jose, CA 95123

5710 Cahalan Avenue, Bldg.2
San Jose, CA 95123
Phone: (408) 227-6444
Fax: (408) 227-5056
www. Kasod.com

*(តមកពីទំព័រទី១)* បិណ្ឌបាតតាមភូមិស្រុកបានឮគេតិះដៀលនិងបណ្ដុះបង្អាប់ដល់ពួកយើងថា ពួកសមណៈជាសាក្យបុត្រ មិនគួរដើរបិណ្ឌបាតក្នុងរដូវវស្សាទេ ជាពិសេសដើរជាន់ស្មៅ ជន្លេន និងសត្វល្អិតៗ ដែលវារចេញមកនៅលើដី នៅពេលភ្លៀងធ្លាក់នេះឡើង។សូម្បីពួកបរិព្វាជក និងពួកអន្យតិរ្ថិយ ដែលជាអ្នកពោលធម៌អាក្រក់និងសត្វស្លាបទាំងឡាយក៏ពួនសំរាកក្នុងរដូវវស្សានេះដែរ។

ព្រះពុទ្ធទ្រង់ព្រះតំរិះថា ពាក្យតិះដៀលរបស់ពួកទាំងនោះ ពិតជាត្រឹមត្រូវ ព្រះអង្គផ្ទាល់ក៏មិនទាន់ បានបញ្ញត្តិការចូលវស្សានេះដែរពេលនោះព្រះអង្គបាន ហៅភិក្ខុទាំងឡាយមកប្រជុំគ្នា ដើម្បីទ្រង់អនុញ្ញាតការ ចូលកាន់វស្សាជាផ្លូវការចាប់ពីពេលនោះមក។

ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឱ្យភិក្ខុសង្ឃចូលកាន់វស្សាមានពីរយ៉ាងគឺៈ

១/ ថ្ងៃចូលវស្សាខាងដើម ហៅថា **បុរិមិកាវស្សា** នៅថ្ងៃ១រោច ខែអាសាឍ រហូតដល់ថ្ងៃ១៥កើតខែអស្សុជទើបចេញ។ ចំណែកឆ្នាំនេះ ព្រះសង្ឃចូលចាំវស្សារហូតដល់១៥កើតខែកត្តិកពីឆ្នាំនេះលើសខែគឺអាសាឍពីរ ដែលហៅថា ទុតិយាសាឍនោះ។

២/ ថ្ងៃចូលវស្សាខាងចុង ហៅថា **បច្ឆិមិកាវស្សា** នៅថ្ងៃ១រោចខែស្រាពណ៍ រហូតដល់១៥កើតខែកត្តិកវិញក៏បាន។

បើភិក្ខុចូលគង់ចាំវស្សានៅទីណាហើយ ត្រូវតែរក្សារាត្រីនៅទីនោះ រហូតគំរប់ពេល៣ខែ។ តែបើភិក្ខុសង្ឃអង្គណាមួយមានធុរៈចាំបាច់ ឬ មានពុទ្ធបរិស័ទនិមន្តបំពេញទាន អាចនិមន្តទៅបានតែប្រញាប់ត្រឡប់មកវិញឱ្យទាន់មុនពេលអរុណរះ។ ប្រសិនមានករណីពិសេសលោកអាចនិមន្តទៅដោយសត្តាហករណីយបាន ៧ថ្ងៃ ត្រូវនិមន្តត្រឡប់មកកាន់វត្តវិញឱ្យទាន់មុនថ្ងៃទី៧បានគឺៈ

**ក**/បើដឹងថាមាតាបិតាឬគ្រូឧបជ្ឈាយាចារ្យមានធុរៈរឺរោគាព្យាធិណាមួយកើតឡើងអាចនិមន្តទៅបាន។



*ពុទ្ធបរិស័ទដង្ហែទៀនវស្សា ប្រគេនព្រះសង្ឃវត្តខេមរង្សី*

**ខ**/ បើមានឧបាសក ឧបាសិកាឬបងប្អូនញាតិមិត្រមានធុរៈឬធ្វើបុណ្យទានអ្វីមួយអាចនិមន្តទៅបានតាមពេលកំណត់។

**គ**/ បើមានគេមកនិមន្ត ក្នុងសង្ឃករណីយកិច្ចណាមួយ អាចនិមន្តទៅបានដែរ។

**ឃ**/បើវត្តអារាមមានប្រធានសក្តិណាមួយកើតឡើងអាចនិមន្តទៅរកបច្ច័យមកកសាងបានជាដើម។

ការចូលវស្សានេះទៀតសោត មិនចំពោះតែភិក្ខុទេ សាមណេរក៏ត្រូវចូលវស្សាដែរ ទើបត្រូវតាមពុទ្ធានុញ្ញាត ប៉ុន្តែសាមណេរមិនចាំបាច់មានកិច្ចការបវរណាទេ គ្រាន់តែធ្វើពិធីអធិដ្ឋានចូលវស្សាប៉ុណ្ណោះ។

បើនិយាយពីប្រទេសកម្ពុជានិងនៅលើទឹកដីកម្ពុជាក្រោមវិញ ជារៀងរាល់ឆ្នាំគណៈកម្មការ អាចារ្យវត្តនិងពុទ្ធបរិស័ទបាននាំគ្នីគ្នារៀបចំពិធីបវរណាព្រះសង្ឃយ៉ាងអធិកអធមនៅគ្រប់វត្តទាំងអស់ ដែលស្របទៅតាមពុទ្ធានុញ្ញាត ដូចប្រទេសនានាដែលកាន់ពុទ្ធសាសនានៅលើសកលលោកអញ្ចឹងដែរ។ នៅពេលរដូវចូលវស្សានេះដែរគឺជាឪកាសល្អហើយមានសារៈប្រយោជន៍យ៉ាងសំខាន់ខ្លាំងណាស់សំរាប់ក្រុមយុវជន ដែលមានសទ្ធាជ្រះថ្លានាំគ្នាមកបួសនិងសំណាក់នៅក្នុងវត្ត ដើម្បីនឹងសិក្សាស្រាវជ្រាវនូវទ្រឹស្តីព្រះពុទ្ធសាសនា ព្រមទាំងអប់រំទូន្មានកាយ វាចា ចិត្ត ឱ្យមានសីលធម៌និងចរិយាធម៌ ស្របទៅតាមគន្លងព្រះពុទ្ធសាសនា។

នៅក្នុងរដូវវស្សា៣ខែនេះ ពុទ្ធបរិស័ទនៅគ្រប់វត្តអារាមទាំងអស់ តែងតែមានការ.. *(តទៅទំព័រទី១១)*

# កិរិយាបរិច្ចាគទានរបស់មនុស្សគ្រប់រូប

ការចូលរួមចំណែកកសាងប្រយោជន៍សំរាប់សសានា និងសង្គមជាតិ ជាការកាតព្វកិច្ចរបស់មនុស្សទូទៅត្រូវបំពេញ ដើម្បីទទួលយកនូវអត្ថប្រយោជន៍ ក្នុងន័យស្ថាបនាមូលដ្ឋានគ្រឹះសំរាប់ខ្លួនឯង និងប្រទេសជាតិ។ព្រះសម្មាសម្ពុទ្ធបានប្រៀនប្រដៅឱ្យពុទ្ធបរិស័ទទាំងអស់ត្រូវចេះធ្វើចិត្តប្រកបដោយសទ្ធាជ្រះថ្លា ព្រមទាំងមានទស្សនៈទូលំទូលាយក្នុងការធ្វើគុណប្រយោជន៍។

មនុស្សយើងតាំងតូចរហូតដល់ធំពេញវ័យ រស់នៅបានដោយសារទាន បានដល់ការជូននូវចំណីចំណុក ចិញ្ចឹមបីបាច់ថែរក្សាពីឪពុកម្តាយ បើពួកគាត់មិនរក្សាយើងរាល់គ្នាទេនោះ យើងប្រាកដជាស្លាប់។យើងអាចមានចំណេះចេះដឹង អានអក្សរសាស្ត្រឬភាសាផ្សេងៗបាន ដោយសារលោកគ្រូ អ្នកគ្រូបានចែករំលែកនូវចំណេះវិជ្ជាដល់យើងសំរាប់ជាប្រទីប ដើម្បីបំភ្លឺខ្សែជីវិតឱ្យមានរស្មីនេះឯង។

ការបរិច្ចាគទានជារឿងសំខាន់បំផុតសំរាប់ជីវិត ព្រោះថាការប្រគល់នូវប្រយោជន៍ឬសេចក្តីសុខដល់អ្នកដទៃ ឈ្មោះថាការឱ្យទាន គឺជាការជួយសង្គ្រោះដល់ជនក្រីក្រ ដូចជាការជួយឧបត្ថម្ភព្រះសង្ឃសិស្សានុសិស្សជួបការលំបាកនៅពេលសិក្សារៀនសូត្រ, ការផ្តល់ឈាមដល់អ្នកជម្ងឺ, ការណែនាំខ្លួនឯងនិងអ្នកដទៃក្នុងផ្លូវល្អ, ការឱ្យអភ័យ មិនចាប់កំហុសអ្នកផងទាំងពួងជាដើម។

យោងតាមទ្រឹស្តីព្រះពុទ្ធសាសនា ប្រភេទនៃការឱ្យទានមានបីប្រការគឺៈ

**ក/ អាមិស្សទាន** បានដល់ការឱ្យនូវសំពត់ខោអាវ គ្រឿងឧបភោគ បរិភោគ លំនៅឋាន ថ្នាំកែរោគ និងសម្ភារៈផ្សេងៗ ជាដើម។

**ខ/ ធម្មទាន** បានដល់ការផ្តល់នូវចំណេះដឹង ការពន្យល់ណែនាំផ្លូវល្អ ការបង្រៀនធម៌អាថ៌ និងការឱ្យនូវវិជ្ជាសាស្ត្រផ្សេងៗជាដើម។

**គ/ អភ័យទាន** បានដល់ការចេះយោគយល់ អធ្យាស្រ័យគ្នា មិនចាប់កំហុសនឹងគ្នា ដែលគេបានធ្វើលើសល្មសដោយអចេតនាមកលើយើង។

បុគ្គលដែលមានទឹកចិត្តសប្បុរសតែងតែអនុគ្រោះចំពោះអ្នកដទៃជានិច្ច សូម្បីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។

ការឱ្យទានរបស់សប្បុរសមាន៥ប្រការគឺៈ

ក/ ឱ្យទានតាមកាល គឺពេលដែលកើតមានអាសន្នឬទទួលរងគ្រោះថ្នាក់ ដូចជាទឹកជំនន់ ខ្យល់ព្យុះ ភ្លើងឆេះផ្ទះ រាំស្ងួត និងជម្ងឺផ្សេងៗ កើតឡើងត្រូវការជំនួយជាបន្ទាន់ឬធ្វើបុណ្យតាមកាល ដូចជាបុណ្យកឋិនទានជាដើម។

ខ/ ឱ្យទានដោយគោរព គឺមិនត្រូវបោះឱ្យឬចោលឱ្យនោះទេ ត្រូវឱ្យដោយអកប្បកិរិយាទន់ភ្លន់ គោរពចំពោះអ្នកទទួលផង។

គ/ ឱ្យទានដោយសទ្ធា គឺជឿថាអំពើដែលធ្វើល្អហើយ នឹងទទួលបានអំពើល្អមកខ្លួនវិញ។

ឃ/ ឱ្យទានដោយអនុគ្រោះ គឺជួយសង្គ្រោះអ្នកដទៃឱ្យបានសុខ មិនមែនឱ្យដោយចង់លុបគុណអ្នកដទៃនោះទេ។

ង/ ឱ្យទានដោយមិនបៀតបៀនខ្លួនឯងនិងមិនបៀតបៀនអ្នកដទៃ គឺមិនលើកតំកើងខ្លួនឯងថា គ្រាន់បើ ហើយមានគំនិតមើលងាយគេឯង។

សូមបញ្ជាក់ថា ប្រសិនបើយើងបានជួបប្រទះនូវវិបត្តិភ័យអន្តរាយគ្រោះថ្នាក់ណាមួយ ពេលនោះចិត្តរបស់យើងចង់ឱ្យគេជួយយកអាសារខ្លាំងណាស់ដោយផ្តល់ជាប្រាក់កាសជាដើម យ៉ាងណាមិញ មនុស្សគ្រប់គ្នាទាំងអស់នៅជុំវិញខ្លួនយើង សុទ្ធសឹងតែត្រូវការជួយសង្គ្រោះអំពីយើងដែរដូច្នេះមនុស្សគ្រប់ត្រូវប្រកាន់យកព្រហ្មវិហារធម៌ទាំង៤ គឺ មេត្តា ករុណា មុទិតា និងឧបេក្ខា មកតំកល់ទុកក្នុងខ្លួនជានិច្ច..... *(តទៅទំព័រទី១០)*

# ការជួបសំណេះសំណាលជាមួយអ្នកទោសគ្មានកំហុសទាំងបីព្រះអង្គ នៅលើទឹកដីសេរីភាព នៃរដ្ឋកាលីហ្វ័រញ៉ា ភាគខាងជើង

នៅទីស្នាក់ការពុទ្ធិកសមាគមខ្មែរកម្ពុជាក្រោម នាវត្តខេមររង្សី ទីក្រុងសាន់ហូសេ រដ្ឋកាលីហ្វ័រញ៉ា ភាគខាងជើង សាខាសហព័ន្ធ គណៈកម្មការ អាចារ្យ វត្តខេមររង្សី និង ពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋាន ជាពិសេស អ្នកស្រឡាញ់លទ្ធិប្រជាធិបតេយ្យ បានរៀបចំពិធីជួបសំណេះសំណាលជាមួយអ្នកទោសគ្មានកំហុសទាំង៣ ព្រះអង្គគឺព្រះតេជគុណ **ទឹម សាខន** ព្រះអង្គ **គឹម មឿន** ព្រះអង្គ **យ៉ាញ់ តួន**កាលពីថ្ងៃទី១៦ខែមិថុនា



*ព្រះតេជគុណ ទឹម សាខន កំពុងមានសង្ឃដីកានៅវត្តខេមររង្សី*

ឆ្នាំ ២០១០ កន្លងទៅហើយនេះ ក្រោមអធិបតីភាព លោក**ថាច់ ខ៉ុក ថាច់** ប្រធានប្រតិបត្តិ នៃសហព័ន្ធខ្មែរកម្ពុជាក្រោម។ដោយមានការនិមន្តនិងអញ្ជើញចូលរួមពីសំណាក់ព្រះសង្ឃ សមាជិក-កានិងអ្នកគាំទ្រសហព័ន្ធខ្មែរកម្ពុជាក្រោមពីក្រុងនានា ដូចជាទីក្រុង San Jose, San Francisco, Oakland, Stockton,និងបណ្តារដ្ឋផ្សេងៗជាច្រើនប្រមាណជាង១៣០អង្គ-រូប។ ក្នុងពិធីជួបជុំនោះ ផ្តោតសំខាន់ទៅលើព្រឹត្តិការណ៍ជាក់ស្តែង ដែលមន្ត្រីសង្ឃខ្មែរអាយ៉ងយួននៅកម្ពុជា ក្នុងនោះមាន ***ឡុង គឹម លាង*** ជាមេក្លោងបាននាំគ្នាប្រើល្បិចថោកទាបបោកបញ្ឆោត ព្រះចៅអធិការវត្តភ្នំដិនខាងជើង **ទឹម សាខ** ឱ្យចេញពីវត្តហើយព្រួតគ្នាចាប់



*អ្នកទោសគ្មានកំហុសទាំង៣ព្រះអង្គ ថតរូបអនុស្សាវរីយ៍ ជាមួយព្រះសង្ឃ គណៈកម្មការវត្តធម្មរង្សី ទីក្រុង Stockton*

បង្ខំដោះស្បង់ចីវរបញ្ជូនទៅឱ្យអាជ្ញាធរយួនដាក់ពន្ធនាគារយួន កាលពី ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧ ក្នុងបទបំបែកបំបាក់ មិត្តភាពមុឺនឆ្នាំ រវាងវៀតណាម-កម្ពុជា។

ទាក់ទិននឹងលោក ឡុង គឹមលាង ព្រះតេជគុណ **ទឹម សាខន** មានសង្ឃដីកាបញ្ជាក់ថា ព្រះអង្គមិនមានគំនិតចងកម្មចងពៀរជាមួយលោកឡុង គឹមលាង ទេ ព្រោះខ្លួនព្រះអង្គជាខ្មែរ ឈាមជ័រជាខ្មែរ ហើយភេទ



**បងប្អូនជនរួមជាតិខ្មែរ-ខ្មែរក្រោម កំពុងស្តាប់សង្ឃដីកា ព្រះតេជគុណ ទឹម សាខន**

ជាអ្នកបួសទៀតត្រូវមានធម៌ខន្តីនិងព្រហ្មវិហារធម៌ជាប់ជានិច្ច តែព្រះអង្គបានសំណូមពរដល់លោក ឡុង គឹមលាងថា ត្រូវចេះគិតនិងពិចារណាឡើងវិញនូវកំហុសឆ្គងរបស់ខ្លួនទាំងប៉ុន្មាន ដែលបានសាងបាបកម្មកន្លងមកនោះ ហើយហ៊ានទទួលយកអ្វីជាការពិត ទើបសមជាកូនខ្មែរ គោរពប្រតិបត្តិ............***(តទៅទំព័រទី១១)***

# ប្រវត្តិសង្ខេបបុណ្យឯករាជ្យជាតិរបស់សហរដ្ឋអាមេរិក

ថ្ងៃបុណ្យឯករាជ្យជាតិរបស់ប្រទេសកម្ពុជា នៅថ្ងៃទី៩វិច្ឆិកា គឺជាថ្ងៃមួយដែលប្រជាពលរដ្ឋខ្មែរចងចាំជាប់ជានិច្ចក្នុងដួងចិត្តគ្មានពេលបំភ្លេចឡើយ។ ចំណែក សហរដ្ឋអាមេរិកវិញនោះ ថ្ងៃបុណ្យជាតិសំខាន់បំផុតរបស់គេ គឺជាថ្ងៃប្រកាសឯករាជ្យ ៤កក្កដា ឆ្នាំ១៧៧៦ ដែលហៅថា July 4 ឬ Independence day នោះ។

បើយោងទៅតាមសៀវភៅប្រវត្តិសាស្រ្ត និងប្រភពនានា កាលពីសតវត្សទី១៦/១៧/១៨ សម័យខ្មែរយើងបោះបង់ចោលប្រាសាទអង្គរវត្ត ដែលត្រូវសៀមនិងពួកយួនឈ្លានពានឬយាយីឥតឈប់ឈរនោះ។ រីឯប្រទេសអង់គ្លេសក៏មានតំបន់អាណានិគមទូលំទូលាយនៅទ្វីអាមេរិកខាងជើងដែរ។

នៅអាមេរិកនិគមជនត្រូវធ្វើការធូន់ធូរដើម្បីរានព្រៃធ្វើចំការថ្នាំ ចំការកប្បាស ពោត សណ្តែក ក៏ពិតមែន តែពួកគេមានសិទ្ធិលើម្ចាស់ដីធ្លី។បញ្ហាចោទរបស់ពួកគេបំផុតនោះ គឺត្រូវបង់ពន្ធឱ្យអង់គ្លេសតាមតែគេកំណត់ ហើយគ្មានអ្នកតំណាងដើម្បីបញ្ចេញមតិប្រឆាំងតវ៉ានៅក្នុងរដ្ឋសភាឡើយ។នៅឆ្នាំ១៧៦៣ព្រះបាទចច្ចទី៣របស់អង់គ្លេសបានទទួលជ័យជំនះ ក្នុងសង្គ្រាមជាមួយនឹងប្រទេសបារាំងនិងពួកស្បែកក្រហម។នៅពេលនោះស្តេចចច្ចបានសំរេចចិត្តដាក់ពន្ធបន្ថែម លើតំបន់អាណានិគមនៅអាមេរិក ដើម្បីបំពេញឃ្លាំងដែលរេចរិលដោយសារសង្គ្រាមរ៉ាំរៃផងនិងដើម្បីដាក់គំនាបគ្រប់គ្រងឱ្យកាន់តែតឹងតែងទៅលើអាណានិមអាមេរិកាំង។ ពន្ធដារឬតាក់ និងច្បាប់ថ្មីបានធ្វើឱ្យអាមេរិកកាន់តែខឹង ហើយនាំគ្នាបះបោរក្រោកឈរឡើង ប្រឆាំងនឹងពួកអង់គ្លេសកាន់តែខ្លាំងក្លាគឺបញ្ហាបង់ពន្ធហ្នឹងឯង។

នៅខែធ្នូ ឆ្នាំ១៧៧៣ សំពៅដឹកទំនិញពីប្រទេសអង់គ្លេសចំនួន៣គ្រឿង ចូលមកសំចតនៅកំពង់ផែក្រុង Boston រដ្ឋម៉ាស្សាឈូសិត្ស តែពួកគយអង់គ្លេសមិនអនុញ្ញាតឱ្យផ្ទេរទំនិញ ទាល់តែបង់តាក់ឱ្យគេជាមុនសិននោះ។ កត្តានេះហើយនាំមានការបះបោរ ពួកបាតុករនាំគ្នាឡើងទៅលើសំពៅ លើកទូរាំងទម្លាក់ចូលទៅក្នុងទឹកសមុទ្រអស់គ្មានសេសសល់ឡើយ។ ប្រតិកម្មទៅនឹងបះបោរលើកនេះ សភាអង់គ្លេសនៅក្រុងឡុងដ៍បានប្រកាសបិទកំពង់ផែក្រុង Boston ចោល នៅខែមីនាឆ្នាំ១៧៧៤ ហើយនៅខែមេសាឆ្នាំ១៧៧៥ សង្គ្រាមបានផ្ទុះឡើង រវាងកងទ័ពអង់គ្លេសនិងពួកបដិវត្តន៍អាមេរិកាំងចាប់ផ្តើមដំបូងនាទីក្រុង Lexington និង Concord រដ្ឋម៉ាស្សាឈូសិត្ស។



*ពលរដ្ឋអាមេរិកបាញ់កាំជ្រួចអបអរសាទ ថ្ងៃបុណ្យឯករាជ្យជាតិ*

ជាងមួយឆ្នាំក្រោយពីកើតសង្គ្រាមមក សភាអាមេរិកាំង ដែលតំណាងឱ្យរដ្ឋអាណានិគមទាំង១៣ ក្នុងសម័យនោះបានបើកកិច្ចប្រជុំលើកទី២នាទីក្រុងហ្វីឡាដឹលហ្វា រដ្ឋផិនសុិលវេនា ហើយបានសំរេចអនុម័តសេចក្តីប្រកាសឯករាជ្យ នៅថ្ងៃទី៤កក្កដា ឆ្នាំ១៧៧៦ផ្តាច់ខ្លួនចេញជាស្ថាពរ ពីមាតុប្រទេសដើម មកជាប្រទេសឯករាជ្យ ហើយបានក្លាយជាមហាអំណាចពិភពលោករហូតនាពេលបច្ចុប្បន្ននេះ។ លោក John Adams មេដឹកនាំម្នាក់ ក្នុងចំណោមអ្នកចុះហត្ថលេខាក្នុងសេចក្តីប្រកាសឯករាជ បានមានប្រសាសន៍អំពីសុទិដ្ឋិនិយមថា សេចក្តីប្រកាសនេះត្រូវបានអបអរសាទរ ក្នុងបុណ្យខួបប្រចាំឆ្នាំរបស់ជនជាតិអាមេរិកាំងពីជំនាន់មួយទៅជំនាន់មួយទៀតឥតស្រាកស្រាន្ត......***(តទៅទំព័រទី១១)***

(តមកពីទំព័រទី៤) ជាដើម។

មនុស្សទុននេះ ពោរពេញទៅដោយភាពប្រកាន់វណ្ណៈ និង រើសអើងជាហេតុធ្វើបរិយាកាសច្របូកច្របល់ អាចបង្កនូវហាយនភាពគ្រប់បែបយ៉ាងទាំងអស់។ ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងថា អ្នកដែលមានចិត្តលោភលន់និងជិះជាន់គេ គឺជាការសាងអំពើបាបដ៏ធ្ងន់ ទោះរត់គេចទៅពួនលើអាកាសក្តី នៅកណ្តាលមហាសមុទ្រក្តី នៅក្នុងរូងភ្នំក្តីក៏នៅមិនរួចផុតពីបាបកម្មនោះបានឡើយ។

សេចក្តីពោលមកខាងលើនេះ គឺចង់បង្ហាញឲ្យដឹងថា មនុស្សយើងស្គាល់តែមុខមាត់ មិនអាចស្គាល់ចិត្តគំនិតពិតប្រាដកទេ។ ដូចនេះយើងត្រូវចំណាយពេលវេលា ក្នុងការសិក្សាស្រាវជ្រាវឲ្យបានស្គាល់ដល់ជំរៅដួងចិត្តរបស់គេ កាលបើស្គាល់ច្បាស់លាស់ហើយ យើងត្រូវឈរលើគោលការណ៍ប្រុងប្រយ័ត្ន និង រក្សាស្មារតីឲ្យរឹងប៉ឹងដើម្បីរិះរកមធ្យោបាយទប់ទល់នឹងល្បិចស្នោកគ្រោក នៃជនដែលមានចិត្តខ្វាក់នោះ ឲ្យវិនាសអន្តរាយពីបរិយាកាសសង្គមព្រមទាំងមិនត្រូវបណ្តែតបណ្តោយខ្លួនឲ្យជនប្រភេទនេះទាក់ទាយទិញទឹកចិត្តយើងបានឲ្យសោះ។ ការកើតមកជាមនុស្សជាការមួយ កម្រណាស់ តែបើបានកើតមកហើយនោះ យើងត្រូវខិតខំសន្សំនូវអំពើល្អ និងប្រកាន់យកភាពយុត្តិធម៌ក្នុងសង្គមជាតិ៕

*ដោយ ថាច់ ចន្ទ្រា*

---

(តមកពីទំព័រទី៧) គ្រប់កាលៈទេសៈទាំងអស់។ ព្រះពុទ្ធបានសំដែងមកថា ចេតនាលះបង់នូវសេចក្តីសុខរបស់ខ្លួនប្រគល់ឱ្យអ្នកដទៃ ដោយមិនគិតពីអត្តប្រយោជន៍ គឺជាអំពើបុណ្យ នឹងទទួលបានផលមកវិញគឺ អ្នកផងទាំងពួងស្រឡាញ់រាប់អានច្រើន, តែងបានត្រឡប់មកវិញនូវសម្បត្តិដោយសុចរិត, កេរ្តិ៍ឈ្មោះតែងផ្សព្វផ្សាយទូទៅថា ជាសប្បុរស, នៅពេលជិតធ្វើមរណកាលទៅ មិនវង្វេងស្មារតី, ពេលស្លាប់ទៅហើយ បានទៅកាន់សុគតិភព គឺឋានសួគ៌និងទេវលោកនាយជាដើម៕

*ដោយ ថាច់ ចន្ទ្រា*

## ដំណឹងសិក្សា
## ភាសាខ្មែរ និងរបាំប្រពៃណីបុរាណខ្មែរ

*ពុទ្ធិកសមាគមខ្មែរក្រោម **វត្តខេមររង្សី** និងក្រុម **របាំអប្សរា** នៅទីក្រុងសាន់ហូសេ្ស មានកិត្តិយសសូមជំរាបជូនដំណឹងដល់បងប្អូនជនរួមជាតិខ្មែរ គ្រប់មជ្ឈដ្ឋាន ឲ្យបានជ្រាប សូមទានជ្រាប ៖*

**** កម្មវិធីសិក្សាភាសាខ្មែរ ជារៀងរាល់ថ្ងៃសុក្រ និងសៅរ៍ ចាប់ពីម៉ោង* **4:00PM - 5:00PM**

**** កម្មវិធីបង្ហាត់របាំប្រពៃណីខ្មែរ ជារៀងរាល់ថ្ងៃសុក្រ ចាប់ពីម៉ោង* **6:00PM - 8:00PM**

*អាស្រ័យហេតុនេះ សូមអញ្ជើញអាណាព្យាបាល និងសិស្សានុសិស្ស គ្រប់ស្រទាប់វណ្ណៈ ដែលមានទឹកចិត្តស្រឡាញ់ និងលើកស្ទួយវិស័យវប្បធម៌ខ្មែរ មេត្តារួសរាន់នាំបុត្តធីតារបស់លោក អ្នក មកសិក្សាភាសាខ្មែរ និងរបាំប្រពៃណីជាតិ ដោយសោមនស្សរីករាយ។*

*** ***ទីកន្លែង:*** *វត្តខេមររង្សី* **1594 Cunningham Ave, San Jose. CA 95122 Tel: (408) 923-2166**

*(តមកពីទំព័រទី៦)* ជួយឧបត្ថម្ភចតុប្បច្ច័យចំពោះព្រះសង្ឃដូចជាចង្ហាន់បិណ្ឌបាត សំពត់សាដក ប្រេង ទៀនវស្សា និងថ្នាំសំរាប់កែរោគជាដើម។ ការដែលឧបាសក ឧបាសិកា មានសទ្ធាជ្រះថ្លាប្រគេនទៀនវស្សាដល់ព្រះសង្ឃ គឺជានិមិត្តនៃបញ្ញាញាណរបស់ព្រះសម្មាសម្ពុទ្ធ ដែលតែងភ្លឺស្វាងជានិច្ចចំពោះសព្វសត្វនិងទេវតាទាំងឡាយ មិនមានពេលណារលត់សោះឡើយ។

**ការប្រារព្ធ:** ក្នុងថ្ងៃចូលវស្សា ពេលល្ងាចថ្ងៃ១៥កើតខែអាសាឍឬទុតិយាសាឍ ពុទ្ធបរិស័ទជួបជុំគ្នានៅតាមវត្តនីមួយៗ ធ្វើពិធីហែទៀនវស្សា សំពត់សាដក និងគ្រឿងបរិក្ខាផ្សេងៗប្រទក្សិណ៣ជុំព្រះវិហារឬអាវាសដែលសង្ឃបានសន្មតិ រួចធ្វើកម្មវិធីពុទ្ធសាសនកិច្ច និមន្តព្រះសង្ឃចំរើនព្រះបរិត្ត សំដែងធម៌ទេសនា ព្រមទាំងវេរទៀនវស្សាប្រគេនដល់ភិក្ខុសង្ឃ។លុះព្រឹកឡើងប្រគេនយាគូនិងចង្ហាន់ចំពោះព្រះសង្ឃផងដែរ។

ប្រវត្តិសង្ខេបនៃបុណ្យចូលវស្សា ដូចបានរៀបរាប់មកខាងលើនេះ សូមពុទ្ធរិស័ទពិចារណានិងសិក្សាស្រាវជ្រាវ ព្រមទាំងអញ្ជើញទៅកាន់វត្តអារាមឱ្យច្រើនកុះករ ដើម្បីកសាងកុសលផលបុណ្យសំរាប់ជាតិនេះនិងទៅអនាគត ជាពិសេសចូលរួមថែរក្សាការពារខឿនវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងទ្រទ្រង់ព្រះពុទ្ធសាសនាឱ្យបានគង់វង្សគ្រប់៥០០០ព្រះវស្សាជានិច្ចនិរន្តរទៅហោង៕

***ដោយ ស៊ឹម សុរិយា***

---

*(តមកពីទំព័រទី៩)* ឡើយ។ លោកបញ្ជាក់ផងថា ទិវានេះត្រូវធ្វើឱ្យឪឡារិកអធិកអធម មានព្យុហយាត្រា មានប្រគុំតន្ត្រី លេងល្បែងកំសាន្ត ប្រកួតកីឡា បាញ់កាំជ្រួច វាយជួង គោះគាំង ដុតភ្នក់ភ្លើង បំភ្លឺពីចុងម្ខាងទៅចុងម្ខាងទៀត នៃទ្វីបនេះជារៀងរហូតទៅ។

សូមបញ្ជាក់ថា សហរដ្ឋអាមេរិក ប្រទេសមួយប្រកាន់យកសិទ្ធិសេរីភាពនិងលទ្ធិប្រជាធិបតេយ្យ គោរពសិទ្ធិមនុស្សពេញលេញ មិនប្រកាន់ពូជសាសន៍ វណ្ណៈ ពណ៌សម្បុរអ្វីទេ ឱ្យតែយើងមានសិទ្ធិរស់ស្របច្បាប់ហើយ។ នៅពេលបុណ្យឯករាជ្យជាតិម្តងៗពលរដ្ឋអាមេរិកាំង ត្រូវបានឈប់សំរាកពីការងារមួយថ្ងៃ ដើម្បីចូលរួមអបអរសាទរ និងធ្វើការគោរពចំពោះអ្នកដែលបានស្លាប់ក្នុងភ្លើងសង្គ្រាមគ្រប់សម័យកាលទាំងអស់។ ជាពិសេសធ្វើពិធីបាញ់កាំជ្រួច ក្នុងន័យបង្ហាញថា ផ្កាភ្លើងដែលបញ្ចេញទៅលើផ្ទៃមេឃាមានពន្លឺយ៉ាងណា មនុស្សជាតិទាំងអស់ត្រូវមានពន្លឺសិទ្ធិសេរីភាព និងឯករាជ្យភាព ភាពស្មើគ្នាយ៉ាងនោះដែរ៕

---

*(តមកពីទំព័រទី៨)* ព្រះពុទ្ធសាសនា ព្រះពុទ្ធបានសំដែងមកថា *«បុគ្គលដែលបានប្រព្រឹត្តខុស ហើយចេះកែប្រែខ្លួនល្អទើបជាបុគ្គលដ៏ប្រសើរ»*។

នៅក្នុងពិធីនោះដែរ ក្រោយពេលបានស្តាប់ថេរដិការបស់ព្រះតេជគុណ**ទឹម សាខន**រួចមក ព្រះសង្ឃនិងពុទ្ធបរិស័ទទាំងអស់សំដែងការសោកស្តាយនូវទង្វើដែលក្រុមមន្ត្រីសង្ឃខ្មែរបានប្រព្រឹត្តទាំងទទឹងទិសមកលើលោកគ្រូ **ទឹម សាខន** ប្រាស់ចាកនឹងសីលធម៌សង្គម ជាពិសេសប៉ះពាល់ដល់កិត្តិយសប្រទេសជាតិ ដែលមានអរិយធម៌រុងរឿងតាំងពីបុរាណកាលមកនោះ។ លោកគ្រូឧទ្ទេសចារ្យទាំងពីរព្រះអង្គបានមានសង្ឃដិកាពីទុក្ខវេទនា ដែលពួកយួនចាប់ដាក់ពន្ធនាគារកន្លងមកហើយសូមអំពាវនាវឱ្យខ្មែរយើងទាំងអស់ត្រូវមានស្មារតីរឹងប៉ឹងកុំចេញបោកល្បិចយួនឱ្យសោះ។ ទីបញ្ចប់ លោក **ថាច់ ង៉ុក ថាច់** បានមានប្រសាសន៍ថ្លែងអំណរអរគុណយ៉ាងជ្រាវជ្រៅចំពោះបងប្អូនជនរួមឈាមទាំងអស់ ដែលបានជួយឧបត្ថម្ភគាំទ្រដល់សហព័ន្ធខ្មែរកម្ពុជាក្រោម ទាំងផ្នែកថវិកា និងផ្នែកស្មារតី ដើម្បីឆ្ពោះទៅកាន់«*សិទ្ធិសំរេចវាសនាខ្លួន ដោយខ្លួនឯង*»៕

***ដោយកូន ខ្មែរ***

# ទូន្មានចិត្តខ្លួនឯងបាន ទើបនៅជាសុខ

នៅពេលដែលមនុស្សគ្រប់រូប កើតទុក្ខ កើតសេចក្តីមិនសប្បាយចិត្ត ឬមានបញ្ហាអ្វីមួយកើតឡើងក្នុងឆាកជីវិតនោះ ត្រូវតែស្វះស្វែងរកវិធីដោះស្រាយណាមួយ ដែលមានប្រសិទ្ធិភាពខ្ពស់ ដើម្បីរំដោះឲ្យចាកផុតអំពីភាពទុក្ខលំបាក ទាំងប៉ុន្មានដែលនឹងកើតមានមកលើសន្តានចិត្តរបស់មនុស្សគ្រប់ៗវ័យបាននោះ *«គឺត្រូវចេះទូន្មានចិត្តរបស់ខ្លួនជាមុនសិន»*។ កាលបើយើងអប់រំទូន្មានចិត្តបានល្អប្រសើរហើយពេលណា យើងនឹងរកឱកាសដោះស្រាយរឿងរ៉ាវស្មុគស្មាញទាំងនោះជាបន្តបន្ទាប់ ព្រោះថា បើយើងមិនបានត្រិះរិះពិចារណាក្នុងការអប់រំបន្ទំកាយ វាចា ចិត្តជាមុនទេ យើងត្រូវដោះស្រាយបញ្ហាដោយអកុសលធម៌គឺ លោភៈ ទោសៈ មោហៈឬដោយកាយទុច្ចរិត វិចីទុច្ចរិត និងមនោទុច្ចរិតជាក់ជាពុំខាន។

វិធីទូន្មានចិត្ត គឺគប្បីតាំងសតិអារម្មណ៍ និង ស្មារតីឲ្យបានរឹងមាំនឹងរំលាយនូវភាពមួហ្មងក្នុងចិត្ត ព្រមទាំងពិចារណាទៅតាមការពិតឲ្យបានល្អិតល្អន់ សិក្សាស្រាវជ្រាវសាឡើងវិញនូវរឿងរ៉ាវដែលកើតឡើង មើលឲ្យឃើញការពិតថាតើរឿងឬបញ្ហាដែលបានកើតឡើងនោះចំ ពោះតែយើងម្នាក់ឯងឬដល់អ្នកដទៃផងដែរ? ជា ធម្មតាទេឆាកជីវិតរបស់មនុស្សយើងរាល់គ្នាគេច មិនផុតរត់មិនរួចពីភាពស្មុគស្មាញឡើយ គ្រាន់តែមានតិច ឬច្រើនប៉ុណ្ណោះ ទៅតាមពេលវេលា និងព្រឹត្តិការណ៍ដែលផ្ទុះឡើង។

ព្រះសម្មាសម្ពុទ្ធ បានសំដែងមកថា ទុក្ខកង្វល់របស់មនុស្សគ្រប់រូបតែងតែកើតមានឡើងក្នុងចិត្តបាននោះ ព្រោះចិត្តរបស់យើងហ្នឹងឯងព្រមទទួលយកហើយ រក្សាទុកវា ម្ល៉ោះហើយចិត្តរបស់យើង នឹងវិលវល់ទៅមិនឆ្ងាយពីអារម្មណ៍ ដូចស្រមោលអន្ទោលតាមប្រាណអញ្ចឹង។

បើចង់បានសុខភាពផ្លូវចិត្ត ក៏ដោយសារការថែរក្សាដែរ កុំចេះតែប្រមូលយកពាក្យឥតប្រយោជន៍ ឥតខ្លឹមសារមកនិយាយជាមួយអ្នកដទៃខ្លាំងពេក នាំឲ្យបាត់បង់ពេលវេលា និងបង្កភ្លើងក្តៅក្រហាយនិងសន្សំទុកចំពោះខ្លួនឯង ដោយអយោនិសោមនសិការ (**ការធ្វើខុស**)។

តាមពិតពាក្យថាទូន្មានចិត្ត គឺជាការចំរើននូវសតិបញ្ញាឲ្យភ្លឺស្វាង ពីព្រោះបញ្ញាជាប្រទីប សំរាប់បំភ្លឺផ្លូវសុចរិត យុត្តិធម៌ ក្នុងការសន្សំនូវកុ សលផលបុណ្យទុកជាស្ពានទៅកាន់ព្រះនិព្វាន និងឋានបរមសុខជាដើម។ យោងតាមទ្រឹស្តីព្រះពុទ្ធសាសនាការអប់រំសតិស្មារតីបានត្រូវប្រកាន់ខ្ជាប់នូវធម៌បីប្រការគឺ សីល សមាធិនិងបញ្ញា មកតំកលទុកក្នុងសន្តានចិត្តរបស់ខ្លួនជាមុនសិន ទើបឈានទៅរកការស្ងប់រម្ងាប់ និងភាពសុខសាន្តបានគ្រប់ពេលវេលា ប៉ុន្តែបើចិត្តអត់បញ្ញាទេ ដូចជាពាក្យថា«ធ្វើខ្លួនឲ្យលំបាកឥតប្រយោជន៍» ។

អាស្រ័យហេតុនេះ ក្នុងនាមយើងជាពុទ្ធសាសនិកជន ដែលគោរពប្រតិបត្តិសាសនាព្រះពុទ្ធ ត្រូវយកចិត្តទុកដាក់សិក្សាស្រាវជ្រាវនូវឱវាទរបស់ព្រះពុទ្ធបរមគ្រូ នៃយើងឲ្យបានច្បាស់លាស់ ដើម្បីពិចារណាក្នុងការកសាងឆាកជីវិត និងសង្គមគ្រួសារឲ្យមានភាពរុងរឿង ថ្កុំថ្កើង។ ពីព្រោះពុទ្ធសាសនា ជាសាសនាមួយ តែងតែណែនាំសព្វសត្វទាំងអស់ក្នុងលោកនេះ អោយស្គាល់ហេតុ ស្គាល់ផល ស្គាល់បុណ្យ ស្គាល់បាបទាំងពេលបច្ចុប្បន្ន និងពេលអនាគត៕

*ដោយ ស៊ឹម ចន្ទ្រា*

# ឧបករណ៍ទ្រខ្សែ២ នៅក្នុងកម្ពុជា

- **ទ្រអ៊ូ** (វង់ភ្លេងមហោរី)
- **ទ្រអ៊ូចំហៀង** (វង់ភ្លេងបាសាក់)

• ទ្រធំ, ទ្រសោធំ, ទ្រសោតូច, ទ្រឆេអ៊ូ,ទ្រឆេសោ

ទ្រទាំងអស់នេះ មានខ្សែសំនៀង២ ខ្សែតូចឈ្មោះខ្សែឯក ខ្សែធំឈ្មោះខ្សែត។ មានព្រលួត២ សំរាប់រឹតខ្សែសំនៀង។ មានខ្សែ.កដូចគ្នាសំរាប់ចងខ្សែសំនៀងទាំង២ឱ្យកៀកទៅនឹងដងត្រង់ក្រោមព្រលួតនោះដើម្បីងាយស្រួលក្នុងការប្រើម្រាមដៃចុចលើខ្សែ។ មានយ៉ងប្រហាក់ប្រហែលគ្នាដាក់លើសន្ទះ ដើម្បីទ្រខ្សែសំនៀងឱ្យផុតពីគែមបំពង់សំនៀង។ ពួកទ្របែបនេះត្រូវដាក់ខ្សែឆាកក្នុងចន្លោះខ្សែសំនៀងទាំង២មិនដាក់ក្រៅដូចឆាកទ្រខ្មែរទេ។ ខ្សែឆាកធ្វើអំពីសំណុំសរសៃសូត្រ, សំណុំជក់ត្នោត, សំណុំកន្ទុយសេះ ឬសំណុំ សរសៃជាងម្នាស់ កាលពីសម័យមុន ប៉ុន្តែបច្ចុប្បន្ននេះ គេយកសំណុំសរសៃជ័រនីឡុងឆ្មារៗមកប្រើជំនួសវិញ។គេយកជ័រឈើស្រល់មករូតចុះឡើងលើខ្សែឆាក ដើម្បីឱ្យខ្សែឆាកជាប់ជិតស្អិតងាយនឹងទាញសំនៀងចេញពីខ្សែទាំងពីរ។ ខ្សែសំនៀងសម័យដើម ធ្វើអំពីសរសៃសូត្រវេញចូលគ្នាបច្ចុប្បន្ននេះ គេប្រើខ្សែលោហធាតុជំនួសវិញ ។ ដង និង ព្រលួតច្រើនតែយកឈើរឹងមកធ្វើដូចជាឈើនាងនួន ឈើខ្មៅ ឈើគ្រញូង។ល។ ចំណែកឯបំពង់សំនៀងគេយក៖

- ចំពោះទ្រអ៊ូមហោរី គេយកត្រឡោកដូងធំៗមានរាងដូចក្បាលដំរីមកធ្វើ យកស្បែកពស់មកពាសធ្វើជាសន្ទះ។

- ចំពោះទ្រអ៊ូចំហៀង គេយកត្រឡោកដូងធម្មតា មកកាត់យកពាក់កណ្ដាលមកធ្វើ យកឈើស្រាលធ្វើសន្ទះ។

- ចំពោះទ្រធំ កាលពីសម័យដើម គេយកប៉ោតប្រេងកាតជ្រុងធុនធំមកធ្វើ បច្ចុប្បន្នគេយកឈើល្អមកក្រឡឹងលុងធ្វើជាបំពង់សំនៀង។




*ឧបករណ៍ភ្លេងប្រពៃណីរបស់ខ្មែរតាំងពីបុរាណកាល*

- ចំពោះទ្រសោធំ គេយកស្នូកអណ្ដើកឬ បំពង់ឫស្សីធុនធំល្មមមកធ្វើបច្ចុប្បន្នធ្វើអំពីបំពង់ឈើ។

- ចំពោះទ្រសោតូច ទ្រឆេអ៊ូ ទ្រឆេសោ គេយកបំពង់ឫស្សីតូចល្មមមកធ្វើឥឡូវនេះគេក្រឡឹងលុងឈើល្អៗដូចជា ឈើនាងនួន ឈើបេង ឈើខ្មៅ ឈើគ្រញូង ឬភ្លុកដំរីធ្វើជា បំពង់ជំនួសវិញ ។ ពួកទ្រនេះគេយកស្បែកពស់មកពាសធ្វើជាសន្ទះ។

- ចំពោះទ្រមានខ្សែ២ ទាំងអស់នេះ នៅពេលកូតម្ដងៗ គេប្រើគល់ម្រាមដៃសំរាប់ចុចលើខ្សែសំនៀងមិនប្រើចុងម្រាមដៃដូចការកូតទ្ររបស់ជនជាតិចិនទេ។

### មុខងារសំខាន់ៗរបស់ទ្រនីមួយៗ ៖

**-ទ្រអ៊ូ៖**

ទ្រនេះមានមុខងារសំខាន់ ចូលរួមប្រគំជាមួយនឹងឧបករណ៍ដទៃក្នុងវង់ភ្លេងការបុរាណ នាដើមសតវត្សទី២០នេះនិងនៅក្នុងវង់ភ្លេងមហោរី ។ ទ្រនេះមានដំណើរសោច់បទមិនដូចទ្រដទៃឡើយគឺសំរាប់ជួយបន្ទរ ឬផ្ដក់ពីមុខ ពីក្រោយ ឬ ស៊កត្រង់កន្លែងចន្លោះៗសាច់បទរបស់ឧបករណ៍ដទៃ............... ***(តទៅទំព័រទី១៤)***

*(តមកពីទំព័រទី១៣)* និងសំរាប់ក្នុងពពួកឧបករណ៍ខាត់សាច់បទភ្លេងក្រោយពួកឧបករណ៍ដទៃ ធ្វើយ៉ាងណាឱ្យសំនៀងរបស់ខ្លួនមានសម្រស់លេចធ្លោផុតពីគេឯងឡើង។

### ទ្រខ្សែសំនៀងបាន២បែបៈនេះរឹត

កាលណាគេយកវាទៅប្រគំក្នុងវង់ភ្លេងការបុរាណគេត្រូវរឹតខ្សែស្មើរីហៅរឹតចំហៀងក៏បានមានចន្លោះ ៤ ប្រសិនបើគេយកវាទៅប្រគំជាមួយឧបករណ៍ដទៃក្នុងវង់ភ្លេងមហោរី គេត្រូវរឹតសោ ឬហៅម្យ៉ាងទៀតថា រឹតភាន់(មានចន្លោះ ៥)។

**-ទ្រអ៊ូចំហៀងៈ**

ទ្រអ៊ូចំហៀងមានមុខងារសំខាន់២យ៉ាង គឺសំខាន់ក្នុងវង់ភ្លេងល្ខោនបាសាក់ និង សំខាន់ម្យ៉ាងទៀតក្នុងវង់ភ្លេងល្ខោនយីកេបច្ចុប្បន្ន។ នៅក្នុងវង់ភ្លេងទាំងពីរនេះទ្រអ៊ូចំហៀងមានតួនាទីផ្តើមចេញបទនាំមុខឧបករណ៍ដទៃក្នុងពេលប្រគំម្តងៗ។ អ្នកចំរៀងទាំងឡាយ និងឧបករណ៍ផ្សេងទៀត ត្រូវរង់ចាំការបើកបទរបស់ទ្រអ៊ូចំហៀងនេះ ជាមុនបន្តិចសិនមុននឹងចូលចំណុចច្រៀង ឬ ចំណុចចេញរបស់ខ្លួន។ ទ្រនេះមានសំនៀងតូចស្រាលជាងទ្រអ៊ូមហោរីពាសស្បែក។

### របៀបរឹតខ្សែសំនៀងមានតែ១បែបគឺ

**-ទ្រធំៈ**

ទ្រធំជាប្រភេទទ្រមួយបែបធុនធំជាងគេ ក្នុងចំណោមទ្រនៅកម្ពុជា។នៅក្នុងរវាងឆ្នាំ ១៩៦០ មាននៅក្នុងរាជវាំង និង ឆ្នាំ១៩៦៤ មាននៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈផ្នែកភ្លេងបុរាណ កាលនោះពួកយើងខ្ញុំនៅជានិស្សិតនៅឡើយ បាននាំគ្នាបង្កើតទ្រធំនេះឡើងធ្វើអំពីឈើខ្នុរ ដើម្បីយកទៅចូលរួមប្រគំសាកល្បងក្នុងវង់ភ្លេងមហោរីវង់ធំ។ ទ្រនេះមានរាងរៅដូចជាទ្រសោធំសុទ្ធសាធ តែរឹតខ្សែដូចទ្រអ៊ូមហោរីទៅវិញ។ ទ្រនេះ មានដំណើរសាច់បទអន្លាយៗមួយៗចំៗមិនបំភ្លៃទេ ។

**- ទ្រសោតូច ៖**




*ក្រុមភ្លេងបុរាណខ្មែរកម្ពុជាក្រោម នៅប្រទេសអូស្ត្រាលី*

ទ្រសោតូចមានមុខងារសំខាន់ដូចជាប្រើប្រាស់ នៅក្នុងវង់ភ្លេងមហោរី វង់ភ្លេងអាយ៉ៃ វង់ភ្លេងការសម័យទំនើប មានក្រុមល្ខោនយីកេខ្លះមិនប្រើទ្រអ៊ូចំហៀងទេ គេប្រើទ្រសោតូចជំនួសវិញ។ ឥឡូវនេះប្រជាពលរដ្ឋបានយកវាទៅប្រើប្រាស់ជាមួយវង់ស្គរដៃយ៉ាំ ជាបណ្តើរហើយនៅក្នុងវង់ភ្លេងជូនរបាំប្រពៃណីខ្លះ ក៏បានយកទ្រសោតូចនេះទៅប្រើប្រាស់ដែរ។សព្វថ្ងៃទ្រសោតូចមានប្រជាប្រិយភាពក្នុងចំណោមប្រជាពលរដ្ឋខ្លាំងណាស់ ជាងទ្រដទៃទៀត។នៅក្នុងវង់ភ្លេងអាយ៉ៃ និងនៅក្នុងវង់ភ្លេងការសម័យទំនើប ទ្រសោតូចមានមុខងារផ្តើមចេញបទមុនគេបង្អស់។ ឧបករណ៍នេះមានរូបរាងតូច ប៉ុន្តែមានសំនៀងខ្លាំង មានដំណើរសាច់បទញឹកចង្អៀតជាងទ្រដទៃ។

### ខ្សែសំនៀងរឹតបាន២យ៉ាងៈ

កាលណាគេយកវាទៅប្រើប្រាស់ក្នុងវង់ភ្លេងមហោរី គេត្រូវរឹតខ្សែសំនៀងរឹតសោ។ កាលណាគេយកវាទៅប្រើប្រាស់ក្នុងវង់ភ្លេងការសម័យទំនើប គេត្រូវរឹតខ្សែសំនៀង រឹតស្មើ។

**- ទ្រឆេអ៊ូ ៖**

ទ្រនេះមានទំហំតូចជាងទ្រសោតូចប៉ុន្តែធំជាងទ្រឆេសោ។ទ្រឆេអ៊ូប្រើប្រាស់បានតែក្នុងវង់ភ្លេងមហោរីប៉ុណ្ណោះ។ទ្រនេះមានដំណើរសាច់ *(តទៅទំព័រទី១៦)*

# ជីវប្រវត្តិសង្ខេប និង ការតស៊ូរបស់វីរសមណៈ ហែម ចៀវ (តពីលេខមុន)

ក្នុងពេលជាមួយគ្នានោះ លោក នួន ឌួង ក៏ត្រូវគិញបារាំងទៅចាប់ងផ្ទះដែរ។នៅពេលដែលបារាំងចាប់ផ្សឹក លោក គ្រូអាចារ្យ **ហែម ចៀវ** មានការឈឺចាប់ឥតឧបមា ធ្វើអោយទឹកនេត្រាលោកហូរដោយមិនដឹងខ្លួនលោកនឹកតូចចិត្តនឹងខ្មែរគ្នាឯងដែលធ្វើធំហើយមិនជួយឈឺឆ្អាលការពារកិត្តិយសព្រះសង្ឃ បែរជាបណ្តោយឱ្យជនបរទេសញាំញីតាមអំពើចិត្តរបស់គេ។ លោកគ្មាននឹកខ្លាចថា បារាំងធ្វើទារុណកម្មអ្វីទេ តែលោកនឹកស្តាយគំរោងការណ៍ ដែលនឹងជិតបានសំរេចផលផ្តល់ទៅអោយប្រជារាស្ត្រខ្មែរ ដែលរស់ក្នុងអន្លង់ទុក្ខក្រោមក្រញ៉ាំបិសាចបារាំង និងស្តេចយង់ឃ្នងជាច្រើនឆ្នាំមកហើយ។នៅក្នុងទីឃុំឃាំង លោកអាចារ្យ **ហែម ចៀវ** អង្គុយសំលឹងតាមរន្ធតូចមួយមើលទៅមេឃាដែលមានដុំពពករសាត់គ្រឿនៗ ប្រៀបដូចជាដុំទុក្ខផុសចេញពីក្រអៅបេះដូងនៃប្រជាជនរួមជាតិ។ ព្រះអាចារ្យពោលតែម្នាក់ឯងទាំងទឹកភ្នែកស្រក់ៈ ឱ! ប្រទេសអញអើយ!តើកាលណាទៅនឹងបានឯករាជ្យ សម្បូសប្បាយដូចសម័យមហានគរវិញ។ បើមន្ត្រីធំៗ សុទ្ធសឹងលក់ក្បាលយ៉ាងដាច់ថ្លៃអោយបារាំងទៅហើយ..។តើថ្ងៃណាទើបខ្មែរយើងក្រោកពីដេក? ទើបខ្មែរស្គាល់ខ្លួនឯងជាមនុស្សដូចសាសន៍ដទៃ!ឱប្រិយមិត្ត!ដែលរួមថ្លើមតស៊ូប្តូរជីវិតឥតស្តាយស្រណោះ។



វត្តអារាមខ្មែរ, វិមានឯករាជ្យ, និងវីរសមណៈ ហែម ចៀវ

ដើម្បីស៊ូគ្រលាស់ខ្លួន អោយរួចពីនឹមអនានិគមបារាំងសែស! មិត្តមិនដឹងជាព្រួយយ៉ាងណាទេ! ព្រោះខ្លាចបែកការណ៍ (ផែនការសំងាត់) របស់យើង! មិត្តអើយ ទោះបីអាចោរអាបលក្សណ៍ទាំងនោះ យកអាវុធមកពុះទ្រូងរូងយកថ្លើមខ្ញុំក៏ដោយ ខ្ញុំមិនឆ្លើយប្រាប់នូវការណ៍ពិតទាំងនោះឡើយ!ខ្ញុំមិនសុខចិត្តឱ្យប្រទេសខ្ញុំស្លាប់ជាដាច់ខាតហើយខ្ញុំមិនសុខចិត្តរស់ ដោយឃើញប្រទេសខ្ញុំកញ្ចះគេដែរ។............*(តទៅទំព័រទី១៧)*



ទិដ្ឋភាពបុណ្យវិសាខបូជា នៅវត្តខេមរវង្សី ទីក្រុងសាន់ហូសេ្ស នៃរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក កាលពីខែឧសភា កន្លងទៅនេះ

*(តមកពីទំព័រទី១៤)* បទដូចទ្រអ៊ូសុទ្ធសាធនិងរឹតខ្សែសំនៀងក៏ដូចគ្នាដែរ។ ឥឡូវនេះស្ទើរតែបាត់បង់វត្តមានពីក្នុងសង្គមកម្ពុជាទៅហើយ។

**-ទ្រឆេសោះ** ទ្រឆេសោមានទំហំតូចជាងគេបំផុត ហើយក៏ឮខ្លាំងជាងគេដែរ។ ទ្រនេះប្រើប្រាស់នៅក្នុងវង់ភ្លេងមហោរី និងនៅក្នុងវង់ភ្លេងល្ខោនបាសាក់។ នៅពេលល្ខោនបាសាក់ទើបតែមកដល់ភ្នំពេញរវាងឆ្នាំ១៩៣០ ទ្រឆេសោមានមុខងារសំខាន់ក្នុងការផ្ដើមចេញបទមុនគេ ប៉ុន្តែមកដល់បច្ចុប្បន្នបែរជាទ្រអ៊ូចំហៀងជាអ្នកផ្ដើមបទវិញ។ ទ្រឆេសោនេះមិនមែនមានកំណើតដំណាលគ្នានឹងកំណើតល្ខោនបាសាក់(ល្ខោនទ្រើងឃ្លោក)មកដល់កម្ពុជានោះទេប៉ុន្តែវាមានកំណើតដ៏យូរលង់ណាស់មកហើយក្នុងវង់ភ្លេងមហោរីរបស់យើង។ សំរាប់បំរើការទាំង២វង់នេះ ទ្រឆេសោត្រូវរឹតខ្សែសំនៀងរឹតសោ។ នៅកម្ពុជាយើងមានវង់ភ្លេងចិនប្រគំក្នុង ពិធីហែអ្នកតា ឬថ្ងៃចូលឆ្នាំប្រពៃណីចិនជារៀងរាល់ឆ្នាំនៅក្រុងភ្នំពេញក្នុងវង់ភ្លេងនោះមានទ្រឆេមួយមានសំនៀងខ្លាំងដូចទ្រឆេសោកម្ពុជាដែរ។ នៅក្នុងវង់ភ្លេងកំដរល្ខោនហ៊ីចិន ដែល ធ្លាប់សំដែងនៅក្នុងកម្ពុជា គេឃើញមានទ្រ ឆេមានតួនាទីសំខាន់ខ្លាំងណាស់ ដូចទ្រឆេសោក្នុងវង់ភ្លេងល្ខោនបាសាក់ដែរ។ខ្ញុំបានឃើញផ្ទាល់៖នៅឆ្នាំ១៩៦៥ ខ្ញុំបានឃើញទ្រសោតូច ប្រគំនៅក្នុងវង់ភ្លេងបុរាណកូរ៉េនៅទីក្រុងព្យុងយ៉ាងប្រទេសកូរ៉េខាងជើង។នៅឆ្នាំ១៩៦៥ ខ្ញុំបានឃើញបែបទ្រសោធំ បែបទ្រសោតូចនិងបែបទ្រឆេមានជាង៤០ធុននៅក្នុងសារមន្ទីរភ្លេងនាទីក្រុងប៉េកាំងប្រទេសចិន។នៅឆ្នាំ១៩៦៧ ខ្ញុំបានឃើញបែបទ្រសោតូចកំពុងប្រគំក្នុងវង់ភ្លេងមួយនៅក្នុងសាលារបាំមួយខាងលិចទីក្រុងតូក្យូប្រទេសជប៉ុន។នៅឆ្នាំ១៩៨៣ ខ្ញុំបានឃើញបែបទ្រសោតូច កំពុងប្រគំនៅក្នុងវង់ភ្លេងមួយក្នុងសាលាសិល្បៈនាទីក្រុងហ្សក់ហ្ស៊ី អតីតសហភាពសូវៀត។ នៅឆ្នាំ១៩៨៥ ខ្ញុំបានឃើញបែបទ្រសោតូច បែបទ្រអ៊ូចំហៀងបែបទ្រឆេ នៅសាលាតូរ្យតន្ត្រីនាទីក្រុងអូឡង់បាទ័រប្រទេសម៉ុងហ្គោលី។ នៅឆ្នាំ១៩៨៥ ខ្ញុំបានឃើញទ្រឆេកំពុង ប្រគំក្នុងវង់ភ្លេងមួយនៅទីក្រុងវៀងច័ន្ទប្រទេសឡាវ។ នៅឆ្នាំ១៩៨៥ខ្ញុំបានឃើញទ្រឆេកំពុងប្រគំជាមួយឧបករណ៍ដទៃទៀតនៅក្នុងវង់ភ្លេងមួយនៅទីក្រុងហាណូយប្រទេសវៀតណាម។ នៅឆ្នាំ១៩៩០ នៅទីក្រុងអូហ្សាការ ប្រទេសជប៉ុន ខ្ញុំបានឃើញគេប្រើទ្រសោតូច កំពុងប្រគំក្នុងវង់ភ្លេងមួយ ។ នៅឆ្នាំ១៩៩២ ខ្ញុំបានឃើញទ្រច្រើនបែប កំពុងប្រគំជាមួយឧបករណ៍ដទៃនៅក្នុងវង់មួយនាទីក្រុងគូឡាឡាំពួរប្រទេសម៉ាឡេស៊ី ។

បែបទ្រខ្សែ២ ដែលមានសណ្ឋានរាងរៅ ប្រហាក់ប្រហែលគ្នា ឬដូចគ្នាសុទ្ធសាធនៅតាមប្រទេសនានាខាងលើនេះ ពិតជាមានទំនាក់ទំនងតាមចរន្តណាមួយពីប្រទេសមួយទៅប្រទេសមួយជាមិនខាន ។ ប៉ុន្តែតាមប្រសាសន៍តន្ត្រីករបុរាណៗភាគច្រើនថាទ្រប្រភេទនេះមានកំណើតនៅប្រទេសចិន ហើយបានខ្មែរធ្វើត្រាប់តាមតាំងពីយូរលង់ណាស់មកហើយខ្ញុំក៏មានការសន្និដ្ឋានបែបនេះដែរ ពីព្រោះប្រទេសចិនជាប្រទេសមានស្តុកស្តម្ភខ្លាំងខាងវិស័យវប្បធម៌ហើយជាប្រទេសដែលធ្លាប់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងប្រទេសកម្ពុជាតាំងពីយូរណាស់មកហើយ ម្យ៉ាងទៀតពាក្យថាសោ ដែលខ្មែរយើងប្រើសព្វថ្ងៃដូចគ្នាសុទ្ធសាធ នឹងពាក្យដើមរបស់ចិនថាSO (មានន័យថាទ្រ) ខ្មែរហៅថាទ្រសោគឺបែបទ្រចិននេះឯង៕



*(តមកពីទំព័រទី១៥)* ឱមិត្តរួមសាសនា! ខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវិញ្ញាណក្ខន្ធនៃវីរបុរសខ្មែរ ដែលមានលោកក្រលាហោមគង់ជាដើម ជួយគាំពារអោយការតស៊ូ របស់យើងបានសំរេចជោគជ័យកុំបីខាន ដើម្បីអោយកូនចៅរបស់យើងស្គាល់នូវសិទ្ធិសេរីភាព យុត្តិធម៌ សុភមង្គល ដូចអារ្យប្រទេសនានា......។

ទំនួញដ៏សោកសៅនេះ បានហើរចូលទៅក្នុងបេះដូងខ្មែរអ្នកស្នេហាជាតិ អោយរឹងរឹតតែក្លាហានឡើង ជាទ្វេភាគ។សេចក្ដីទុក្ខលំបាករបស់លោក ដែលបារាំងបានធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ដើម្បីសួរចំលើយនោះ មានវិសាលភាពមិនអាច ពណ៌នាបានឡើយ។ រីឯលោក **នួន ឌួច** ធ្វើការនៅក្រុមជំនុំប្រែព្រះត្រៃបិដក ក៏ត្រូវទទួលអំពើយង់ឃ្នង ដូចព្រះអាចារ្យ **ហែម ចៀវ** ដែរ តែវីរបុរសទាំងពីររូបនេះ បានរក្សាទុកកិត្តិយសខ្មែរយើងរហូតមកដល់សព្វថ្ងៃ ។

**មហាបាតុកម្មថ្ងៃ២០ កក្កដា ១៩៤២** ដំណឹងបារាំងចាប់ផ្សឹកលោកគ្រូអាចារ្យ **ហែម ចៀវ** បានធ្វើអោយសាមណសិស្សនៅសាលាបាលីជាន់ខ្ពស់រំជើបរំជួលយ៉ាងខាំង ហើយផ្សាយទៅគ្រប់វត្តអារាមនិងខេត្តក្រៅដើម្បីរួមប្រជុំគ្នា ធ្វើបាតុកម្មតវ៉ាអោយបារាំងដោះលែងលោកគ្រូអាចារ្យ **ហែម ចៀវ** និងលោក **នួន ឌួច** ពីទីឃុំឃាំងមកវិញ ។ មហាបាតុកម្មនេះ បំរុងធ្វើនៅថ្ងៃទី១៨ កក្កដា តែត្រូវអាក់ខានទៅវិញ ដោយនៅវត្តលង្កាជាប់រវល់ធ្វើបុណ្យចំរើនព្រះជន្មវស្សាព្រះធម្មលិខិត **ល្វី ឯម** ជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ ក្នុងឱកាសដែលលោកឡើងសមណស័ក្តិទីជាព្រះធម្មលិខិត។ពិធីបុណ្យនេះបានបង្ហើយនៅថ្ងៃទី១៩កក្កដា។ពេលនោះលោក**សឺង ង៉ុកថាញ់** បានភៀសខ្លួនទៅពួនឯការិយាល័យកងអាវុធហត្ថជប៉ុនដើម្បីគេចខ្លួនអោយផុតពីកន្ទាប់ដៃបារាំងសែស ក្នុងគោលបំណងដឹកនាំក្រុមបដិវត្តន៍ក្នុងការរំដោះជាតិអោយបានសំរេច។ ការទាក់ទងរវាងលោក **សឺង ង៉ុកថាញ់** និងមេដឹកនាំខាងបាតុកម្មបានប្រព្រឹត្តទៅយ៉ាងសកម្ម ដោយមានលោក **ប៉ុណ្ណ ចន្ទម៉ុល** ជាអ្នកនាំពាក្យទៅជំរាបលោក **ប៉ាច ឈឿន** ដែលជាបុរសម្នាក់មានចិត្តរឹងដូចថ្ម។ រាត្រីថ្ងៃទី១៩កក្កដា មេដឹកនាំពួកបាតុករបានរៀបចំក្បួនដោយក្រុមៗ តាមកម្មវិធីរបស់ខ្លួនជាស្រេច។

ថ្ងៃទី២០កក្កដាក៏ចូលមកដល់....ប្រជារាស្ត្រនិងព្រះសង្ឃខ្មែរ នៅទីក្រុងភ្នំពេញដៃកាន់ដងបដា ដើរសំដៅទៅវិមានទេសាភិបាលបារាំងនៅខាងលិចវត្តភ្នំ (ទីស្តីការរដ្ឋមន្ត្រីក្រសួងផែនការសព្វថ្ងៃ) ប្រកបដោយទឹកមុខអង់អាចក្លាហាននិងខឹងផង។ នៅខាងលើផ្ទាំងបដានោះ មានចារិកពាក្យស្លោកថា *«យើងខ្ញុំសូមអោយដោះលែងលោកគ្រូអាចារ្យ **ហែម ចៀវ** និងលោក **នួន ឌួច** មកវិញ »*។ ពួកបាតុករ បានទៅដល់ការិយាល័យទេសាភិបាលបារាំងយ៉ាងកុះករ ដោយចំរុះដោយពណ៌លឿងផង ធ្វើអោយទិដ្ឋភាពនេះគួរគយគន់ឥតគណនា។ នៅមុខពួកបាតុកររាប់ម៉ឺននាក់ គេក្រលេកឃើញលោក **ប៉ាច ឈឿន** ឈរយ៉ាងសង្ហាគ្មានព្រឺរោមខ្លាចពួកបារាំងយង់ឃ្នងធ្វើបាបអ្វីឡើយ។ មុនដំបូងលោក**ប៉ាច ឈឿន**បានរ៉យរ៉ាប់ប្រាប់បារាំងពីហេតុការណ៍ផ្សេងៗនិងសុំជួបទេសាភិបាលបារាំង តែបារាំងអោយចូលពីរបីនាក់ប៉ុណ្ណោះ។ ក្រុមបាតុករមិនព្រមព្រោះខ្លាចពួកវាចាប់ទៀត ។ ពេលនោះដោយមនុស្សប្រាលចុះប្រាលឡើងធ្វើអោយលោក**ប៉ាច ឈឿន**ជ្រុលខ្លួនចូលក្នុងបេងការិយាល័យរបស់បរទេស ហើយបារាំងក៏បិទទ្វាររួចវានាំមេបាតុករតាមផ្លូវក្រោយបាត់ទៅ។ ការបះបោរវាយដូច្នេះ ធ្វើអោយខូចគំរោងការអស់រលីង ដែលលោក**សឺង ង៉ុកថាញ់** បានទាក់ទងអោយជប៉ុនជួយធ្វើអន្តរាគមន៍ បើប្រសិនណាទេសាភិបាលបារាំងមិនដោះលែងវីរជនទាំងពីរទេ (សូមអានគុកនយោបាយរបស់លោក **ប៉ុណ្ណ ចន្ទម៉ុល**)............ ***តទៅលេខក្រោយទៀត***

# ខ្មែរកម្ពុជាក្រោម១៧គ្រួសារតវ៉ារឿងដីធ្លី ដែលវៀតណាមយកធ្វើសហករណ៍

ពលរដ្ឋខ្មែរកម្ពុជាក្រោមចំនួន ១៧គ្រួសារ រស់នៅខេត្តឃ្លាំងទឹកដីកម្ពុជាក្រោមដែលបច្ចុប្បន្នគ្រប់គ្រងដោយប្រទេសវៀតណាម បាននាំគ្នាទៅតវ៉ាបញ្ហាដីធ្លីរបស់ខ្លួននៅការិយាល័យគណៈកម្មាធិការជនជាតិ និងតំបន់ភ្នំប្រទេសវៀតណាម ដែលរដ្ឋាភិបាលយកធ្វើសហករណ៍ក្នុងរង្វង់ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៨៥ ហើយបានប្រគល់ឲ្យអ្នកផ្សេងទៅវិញ។

ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមចំនួន ១៧នាក់តំណាងឲ្យ១៧គ្រួសារ រស់នៅខេត្តឃ្លាំង ទឹកដីកម្ពុជាក្រោមនៅព្រឹកថ្ងៃច័ន្ទទី២៨ខែមិថុនា បាននាំគ្នាទៅតវ៉ានៅក្រុងគិនធើ ឬ ព្រែកឫស្សីប្រទេសវៀតណាម ដើម្បីសុំឲ្យអាជ្ញាធរវៀតណាមដោះស្រាយបញ្ហាដីធ្លីឲ្យពួកគេវិញ។

ស្ត្រីខ្មែរកម្ពុជាក្រោមម្នាក់ ក្នុងចំណោមអ្នកតវ៉ា ១៧នាក់ដែលសុំឲ្យវិទ្យុអាស៊ីសេរីកុំបញ្ចេញឈ្មោះបានប្រាប់ឲ្យដឹងថា ពួកគាត់ជាអ្នកស្រុកបឹងអន្សា ខេត្តឃ្លាំងបាននាំគ្នាឡើងមកតវ៉ាសុំឲ្យអាជ្ញាធរប្រទេសវៀតណាម នៅការិយាល័យគណៈកម្មាធិការជនជាតិ និងតំបន់ភ្នំ ប្រចាំក្រុងគិនធើ ឬព្រែកឫស្សី ដោះស្រាយបញ្ហាដីធ្លីរបស់ពួកគាត់១គ្រួសារ៣ទៅ៤ហិកតារ ដែលរដ្ឋាភិបាលវៀតណាមយកធ្វើសហករណ៍ ក្នុងរង្វង់ឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៨៥។ ស្ត្រីរូបនេះបន្តថា នៅក្រោយឆ្នាំ១៩៨៥ សហករណ៍បានរំសាយ រដ្ឋាភិបាលវៀតណាមមិនបានប្រគល់ឲ្យពួកគេវិញឡើយ ហើយបានប្រគល់ឲ្យអ្នកផ្សេង។ មិនត្រឹមតែប៉ុណ្ណោះ នៅពេលដែលពួកគាត់តវ៉ាខ្លាំង អាជ្ញាធរមិនបាននៅដោះស្រាយឲ្យពួកគាត់ឡើយ ហើយបែរជាមានក្រុមជនពាលទៅគំរាមកំហែងពួកគាត់ទៅវិញ។

*«រឿងដីធ្លីហ្នឹងណា៎ គេមកកាប់សម្លាប់ដល់ផ្ទះពីឆ្នាំ៩១ មកឥឡូវវាចែកឲ្យគ្នាវាធ្វើហើយ វាមិនព្រមជំនុំឲ្យ ហើយឥឡូវវាធ្វើបាប វាធ្វើហួសហើយ ឆ្នាំ ៩០ គត់ម្ល៉េះ វាចុះយកដីទឹកហ្នឹង វាមិនព្រមសង ឲ្យមកជួយផងឥឡូវ ខ្ញុំកំពុងពិបាកវេទនា វាគ្មានជួយអីទាំងអស់»។*



*លោក រិន បា ត្រូវតុលាការកុម្មុយនិស្តយួនទាក់ទិនបញ្ហាដីធ្លី*

វិទ្យុអាស៊ីសេរីបានព្យាយាមទាក់ទងទៅមន្ត្រីស្ថានទូតវៀតណាម ប្រចាំនៅកម្ពុជា ដើម្បីបំភ្លឺជុំវិញបញ្ហានេះ ក៏ប៉ុន្តែពុំមានអ្នកទទួលទូរស័ព្ទ។អ្នកនាំពាក្យសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោកព្រះភិក្ខុ ព្រះនាមថាច់ ស៊ុរី មានព្រះថេរៈដីកាថា ការតវ៉ារបស់ពលរដ្ឋខ្មែរកម្ពុជាក្រោម បានអូសបន្លាយតាំងពីឆ្នាំ២០០០ មកម្ល៉េះពុំមានការ ដោះស្រាយជូនប្រជាពលរដ្ឋឡើយ ហើយរដ្ឋាភិបាលវៀតណាម បានចាប់ខ្លួនតំណាងពលរដ្ឋដាក់ពន្ធនាគារថែមទៀត ដែលជាហេតុធ្វើឲ្យពលរដ្ឋខ្មែរកម្ពុជាក្រោមមានការរុញរាមិនហ៊ានធ្វើការតវ៉ា។

*«ដែលគាត់ចេញច្បាប់រដ្ឋធម្មនុញ្ញមាត្រទី ៦៧ នោះទេគាត់ថាយើងតវ៉ាដើម្បីឆ្លៀតឱកាសធ្វើនយោបាយ អ៊ីចឹងហើយអាត្មាភាពក្នុងនាមអ្នកនាំពាក្យសហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំព្រះរាជាណាចក្រកម្ពុជា អាត្មាសុំបដិសេធ ពីព្រោះថា សហព័ន្ធពុំមានដឹកនាំឲ្យបងប្អូនទៅតវ៉ាទេនេះដោយការភ្ញាក់រលឹករបស់បងប្អូន អត់ឃ្លានស៊ីគាត់ឈឺចិត្ត ប៉ុន្តែរដ្ឋាភិបាលយួននៅតែចោទដើម្បីយកលេសនយោបាយដើម្បីបង្ខិត ឬគំរាមបងប្អូនកុំឲ្យចេញតវ៉ាបាន»។*

ប្រភពពីអ្នកតវ៉ាបានឲ្យ....... ***(តទៅទំព័រទី២៩)***

# ស្ត្រី១០រូបក្លាយជាសេដ្ឋីនីដោយសារ ការរកស៊ីដោយខ្លួនឯង



ស្ត្រីអ្នកជំនួញវ័យនៅអាស៊ី ដែលមានទ្រព្យសម្បត្តិច្រើន

ស្ត្រី១០រូប ដែលក្លាយជាសេដ្ឋីនីដោយសារការរកស៊ីដោយខ្លួនឯងមិនពឹងផ្អែកលើកេរដំណែល ត្រូវបានបង្ហាញដោយវេបសាយមួយកាលពីពេលថ្មីៗកន្លងមក។ស្ត្រីទាំងនេះស្ថិតក្នុងចំណោមមហាសេដ្ឋីចំនួន១.០១១នាក់លើពិភពលោក។ សេដ្ឋីនីទាំង១០រូបនោះមានបង្ហាញជូនដូចខាងក្រោមនេះ៖

១-លោកស្រី Wu Yajun ជាជនជាតិចិន បច្ចុប្បន្នជានាយកប្រតិបត្តិនៃក្រុមហ៊ុនអភិវឌ្ឍន៍ អចលនទ្រព្យឈ្មោះ Longfor Proper-ties មានប្រាក់សរុបចំនួន៣,៩ពាន់លានដុល្លារអាមេរិក។

២-លោកស្រី Rosalia Mera ជាជនជាតិអេស្ប៉ាញ បច្ចុប្បន្នជាសហម្ចាស់ក្រុមហ៊ុនសារជីវកម្មមួយឈ្មោះថា Inditex និងជាសហម្ចាស់ ក្រុមហ៊ុនផលិតនិងលក់សំលៀកបំពាក់ធំមួយ។ លោកស្រី Rosaila Meraមានប្រាក់សុទ្ធចំនួន៣,៥ពាន់លានដុល្លារអាមេរិក។

៣-លោកស្រី Elena Baturina ជាជនជាតិរុស្ស៊ី ភរិយារបស់លោក Yuri Luzh- kov អភិបាលក្រុងម៉ូស្គូប្រទេសរុស្ស៊ី។លោកស្រី Elena Baturina ជាអ្នកមានបំផុតនៅប្រទេសរុស្ស៊ី ដោយលោកស្រីមានប្រាក់សរុបចំនួន២,៩ពាន់លានដុល្លារអាមេរិក ។

៤-លោកស្រី Duris Fisher ជាជនជាតិអាមេរិក បច្ចុប្បន្នជាសហស្ថាបនិកក្រុមហ៊ុនលក់សំលៀកបំពាក់ដ៏ធំមួយមានប្រាក់សរុបចំនួន ២,៤ពាន់លានដុល្លារអាមេរិក៥-នាង Oprah Winfrey ជាជនជាតិអាមេរិកបច្ចុប្បន្ន ជាអ្នករៀបចំកម្មវិធីជជែកកំសាន្តតាមទូរទស្សន៍ដ៏ល្បីឈ្មោះ មានប្រាក់សរុបចំនួន២,៤ពាន់លានដុល្លារអាមេរិក។

៦-លោកស្រី Giuliana Benett ជាជនជាតិអាមេរិក មានប្រាក់សរុបចំនួន២,១ពាន់លានដុល្លារអាមេរិក។

៧-នាង Chu Lam Yiu ជាចិនហុងកុង បច្ចុប្បន្នជានាយិកាក្រុមហ៊ុនមួយឈ្មោះ Hua bao International មានប្រាក់សរុបចំនួន២,១ពាន់លានដុល្លារអាមេរិក។

៨-លោកស្រី Zhang Xin ជាជនជាតិចិន បច្ចុប្បន្ន ជាសហស្ថាបនិកក្រុមហ៊ុនអភិវឌ្ឍន៍អលចនទ្រព្យមួយមានប្រាក់សរុបចំនួន ២ពាន់លាន ដុល្លារអាមេរិក។

៩-លោកស្រីMeg Whitmanជាជនជាតិអាមេរិក អតីតប្រធានក្រុមហ៊ុនដាក់លក់របស់របរផ្សេងៗតាមអ៊ីនធើរណេតហើយបច្ចុប្បន្នបេក្ខជនគណបក្សសាធារណរដ្ឋសំរាប់តំណែងអភិបាលរដ្ឋកាលីហ្វ័រនីញ៉ា។

១០-លោកស្រី J.K Rowling ជនជាតិអង់គ្លេស អ្នកនិពន្ធរឿងភាពយន្តហារីផលធ័រមានប្រាក់សរុបចំនួន១ពាន់លានដុល្លារអាមេរិក៕

# នារីដែលប៉ិនប្រសប់កិច្ចការផ្ទះនិងរំលែកកិច្ចការមួយចំនួនរបស់ប្ដីគឺជាការផ្ដល់សិរីសួស្ដីក្នុងគ្រួសារ




*ក្រុមស្ត្រីដែលប៉ិនប្រសប់ឬជំនាញខាងកិច្ចការវិជ្ជាមេផ្ទះ*

ក្នុងមួយថ្ងៃៗបុរសជាប្ដីតែងតែខំបំពេញការងារអស់ពីកម្លាំងចិត្ត និងកម្លាំងកាយក្រោមកំដៅព្រះអាទិត្យបែកញើសហូររហាមនៅឯចំការ ឬនៅការិយាល័យរដ្ឋ-ឯកជន ដើម្បីយកប្រាក់មកចិញ្ចឹមគ្រួសារ ហេតុនេះប្រពន្ធនៅឯផ្ទះគួរណាស់គិតអាណិតអាសូរដល់ប្ដី ត្រូវចេះចូលរួមខិតខំធ្វើការនៅក្នុងផ្ទះឬបើថាទៅធ្វើការនៅឯការិយាល័យរដ្ឋ-ឯកជនខាងក្រៅក្ដីក៏មិនត្រូវភ្លេចភាពជាមេផ្ទះដែរ គឺត្រូវរៀបរយនិងបំពេញករណីយកិច្ចចំពោះប្ដីនិងគ្រួសារឱ្យបានសមរម្យ។ មុននឹងចាយវាយអ្វីមួយត្រូវគិតពិចារណាពិគ្រោះនឹងប្ដីសិន កុំចាយតាមចំណង់ ។

ស្ត្រីខ្លះក្នុងមួយថ្ងៃៗ គិតតែចាយវាយខ្ជះខ្ជាយបរិភោគចំណីអាហារណាឆ្ងាញ់ៗ តែម្នាក់ឯងដោយគ្មាននឹកនាដល់ប្ដីដែលខំរកប្រាក់នៅខាងក្រៅសោះ។ យើងជាស្ត្រីមិនត្រូវហ៊ឺហាសប្បាយតែម្នាក់ឯង ដោយគ្មានយល់ដឹងដល់កម្លាំងរបស់ប្ដីនោះទេ ចូរនាងកុំគិតថាអាងតែខ្លួនជាប្រពន្ធគេ ត្រូវតែប្ដីរកប្រាក់មកចិញ្ចឹមខ្លួនឱ្យសប្បាយនោះបើប្ដីចេញទៅធ្វើការនៅខាងក្រៅ ខ្លួនយើងជាស្ត្រីត្រូវចេះបំពេញកិច្ចការនៅក្នុងផ្ទះ ឱ្យបានស្អាត ចេះជួយសន្សំប្រាក់ប្ដីកុំខ្ជីខ្ជាទើបមានសុភមង្គលនិងសេចក្ដីថ្លៃថ្នូរ។ ទោះជាប្ដី រហេមរហាមយ៉ាងណាក៏អ្នកនាងមិនត្រូវប្រមាថមើលងាយប្ដីដែរ ហើយបើនាងមិនរវីរវល់គិតដល់ប្ដីនោះ មានន័យថា នាងចង់សម្លាប់ប្ដី លើសពីនេះទៀតអ្នកផងគេនឹងសើចពេបជ្រាយនូវគំនិតដ៏អាក្រក់របស់នាង ដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន។ ការប្រព្រឹត្តបែបនេះគេហៅថា ស្រីខាតលក្ខណ៍ទីបំផុតសុភមង្គលមិនអាចកើតមានឡើយ គឺកើតមានតែការបែកបាក់គ្នាប៉ុណ្ណោះ។

បើអ្នកនាងមិនបានជួយរកផ្សំនូវអំពើល្អណាមួយសូមអ្នកនាងកុំធ្វើឱ្យប្ដីរកាំរកូសផ្លូវចិត្តឱ្យសោះ បើនាងចេះស្រឡាញ់ប្ដី អាណិតប្ដី គួរណាស់តែអ្នកនាងគិតពីកម្លាំងប្ដីផង ចាយវាយឱ្យមានសណ្ដាប់ធ្នាប់.......ចេះគោរពលើកកំពស់កិត្តិយសប្ដីចេះជួយការងារប្ដីមិនត្រូវស្ពឹកស្រពន់ត្រូវតែរវាសរវៃយល់ដឹងរាក់ជ្រៅក្នុងសង្គម ទើបភាពចំរុងចំរើន សិរីសួស្ដី កើតឡើងនិងមានមុខមានមាត់ដល់គ្រួសារ អ្នកជិតខាងកោតសរសើរយកគំរូតាម។បុរសណាបានជួបប្រទះប្រពន្ធដែលគិតតែចាយវាយគ្មានគិតកម្លាំងប្ដី មិនលើកមុខនិងជួយប្ដី មុខជារងទុក្ខវេទនាអស់មួយជីវិត ទោះបីប្ដីខំរកទាំងយប់ទាំងថ្ងៃយ៉ាងណាក៏មិនឈ្នះនឹងប្រពន្ធ ដែលចាយគ្មានពិចារណានោះដែរហើយថែមទាំងមិនមានកិត្តិយសក្នុងសង្គមទៀតផង។

ការលើកទឹកចិត្តដល់ប្ដីម្យ៉ាងទៀតគឺពេលប្ដីមកពីធ្វើការវិញត្រូវចេះយកចិត្តទុកដាក់ជាមួយប្ដី ដូចជាសួរថាបងថ្ងៃនេះហត់នឿយទេ ?មានកិច្ចការអ្វីឱ្យខ្ញុំជួយទេ ? និយាយបណ្ដើរជួយដោះអាវឱ្យប្ដីបណ្ដើរបន្ទាប់មកយកទឹកឱ្យប្ដីពិសា រៀបចំកន្លែងឱ្យប្ដីអង្គុយឱ្យស្រួលបួលហាមកូនកុំឱ្យស្រែកយំឬស្រែក ឡូឡា ព្រោះប្ដីដែលទើបមកពីធ្វើការហត់នឿយមាន....*(តទៅទំព័រទី២៨)*

# ព្រះពុទ្ធសាសនា និងយុត្តិធម៌

យើងគប្បីចាប់ផ្តើមដោយការសិក្សានូវពាក្យថា រាជា( King )។បើតាមសៀវភៅឈ្មោះព្រះបាទធម្មិក បានអះអាងថា ពាក្យថា"រាជា"នេះ ជាសម្រែករបស់មហាជនស្រែកសំដែងនូវក្តីរីករាយអំណរសាទរ ចំពោះបុគ្គលណាម្នាក់ ដែលបានបំពេញការងារជាប្រយោជន៍ ឬការពារពួកគេរហូតដល់ពួកគេពេញចិត្ត,ពេញប្រមាត់ មិនអាចទប់ចិត្តបានហើយបញ្ចេញសំលេងថា រាជា ! រាជា !ដែលមានន័យថា «ពេញចិត្តហើយ» ! ពេញចិត្តហើយ!ឬថា«ពេញចិត្តណាស់»!ពេញចិត្តណាស់!។

ដោយឃើញថា បុគ្គលនោះមានសមត្ថភាព និងគុណធម៌លើសគេទាំងពួង ធ្វើអោយពួកគេពេញចិត្ត ទុកចិត្ត ស្រលាញ់ចូលចិត្ត ទើបពួកគេប្រគល់នូវនាទីអោយបុគ្គលនោះ ជាអ្នកមើលការខុសត្រូវលើពួកគេជាអ្នកសំរេចលើជោគវាសនារបស់ពួកគេ នាំពួកគេទៅណាពួកគេនឹងទៅតាម។ ពេលមានវិវាទកើតឡើងម្តងៗ បុគ្គលនោះជាអ្នក សំរេចថា ពួកគេមួយណាជាអ្នកខុស និងមួយណាជាអ្នកត្រូវនិងសំរេចចិត្តថាបុគ្គលណាគួរដល់នូវការលើកតំកើងបុគ្គលណាគួរដល់នូវការផ្តាញ់ផ្តាល។បុគ្គលនោះត្រូវបានគេហៅថា រាជា ដែលមានន័យថា«បុគ្គលជាទីពេញចិត្តជាទីទុកចិត្ត»។

ប្រការនេះក៏មានចែងនៅក្នុងសៀវភៅកប្បកដ្ឋា ដែលនិយាយពីការវិវត្តន៍ដំបូងៗ របស់មនុស្សនិងពិភពលោកផងដែរ។

រាប់ពាន់ឆ្នាំក្រោយមក បុគ្គលជា រាជានោះ មិនសូវបំពេញការងារអោយជាទីពេញ ចិត្តរបស់ពួកគេដូចជាលំអៀង, ឃោឃៅព្រៃផ្សៃ និងភាពល្មោភជាដើម។ចាប់ពីពេលនោះមក តំណែងជារាជា ជាតំណែងដែលភាគច្រើនបានមកដោយការដណ្តើមគ្នា។ បុគ្គលខ្លះមានសមត្ថភាពដណ្តើមយកតំណែងនេះហើយក៏ធ្វើអោយមនុស្ស ស្រលាញ់ចូលចិត្តបានច្រើន ចំណែកអ្នកខ្លះមិនមានគុណធម៌ មិនមានយុត្តិធម៌ ក៏ប្រើសិទ្ធិប្រើអំណាចរបស់ខ្លួនក្នុងនាមជារាជានោះ ដើម្បីប្រព្រឹត្តធ្វើអំពើសាហាវ ព្រៃផ្សៃ ជិះជាន់ កាប់សំលាប់ រឹបអូសយករបស់ណាដែលខ្លួនចង់បានតាមទំនើងចិត្ត ហើយចង់សំរេចដាក់ទោសទណ្ឌកម្មបុគ្គលណា អោយបុគ្គលណាស្លាប់ ឬរស់តាមតែអណ្តាតរបស់ខ្លួន ដោយពុំគិតពីគុណធម៌ឬយុត្តិធម៌ជាដើម។ពាក្យថារាជា ក៏ក្លាយទៅជាពាក្យគេសំគាល់លើបុគ្គល ដែលមានសិទ្ធិអំណាចជាងគេជាងឯងគឺស្តេច ប៉ុន្តែគេមិនសូវបានគិតដល់អត្ថន័យនៃពាក្យនេះឡើយ។



*ការគោរពប្រតិបត្តិព្រះពុទ្ធសាសនា នៃសង្គមខ្មែរសព្វថ្ងៃ*

នៅក្នុងមហាបទុមជាតក៏ ព្រះពុទ្ធបានសំដែងអំពីគោលធម៌សម្រាប់បុគ្គលជាស្តេចប្រតិបត្តិ ដែលត្រូវបានគេស្គាល់ថាទសពិធរាជធម៌ គឺធម៌ ឬគោលការណ៍ ១០ យ៉ាងសម្រាប់ស្តេច ឬបុគ្គលដែលជាអ្នកដឹកនាំ។

បច្ចុប្បន្ននេះ រាជា ឬ ស្តេច បានសាបរលាបអស់ពីប្រទេសមួយចំនួនបើទោះជានៅក៏រាជានោះ មិនសូវមានការកាតព្វកិច្ចច្រើនដូចពីអតីតកាលដែរ។ ជាតួយ៉ាងដូចជានៅប្រទេសកម្ពុជា ព្រះរាជាទ្រង់គង់ជាម្លប់តំណាងឯករាជជាតិ អធិបតេយ្យភាពនិង ឯកភាពជាតិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។ សិទ្ធិអំណាចនិងកាតព្វកិច្ចភាគច្រើនរបស់ព្រះរាជាពីអតីតកាល បានត្រូវគេប្រគល់ទៅឱ្យបុគ្គលម្នាក់ផ្សេងទៀត ដែលនៅប្រទេសខ្លះគេហៅថា នាយករដ្ឋមន្ត្រី... ***(តទៅទំព័រទី២៦)***

# បង្ហាញរូបថតទាហានអាល្លឺម៉ង់មាឌធំចុះចូលជាមួយទាហានមាឌតូចម្នាក់

នៅន័រម៉ង់ឌី ប្រទេសបារាំង រូបថតមួយបង្ហាញពីទាហានមាឌតូចម្នាក់ចាប់ខ្លួនទាហានអាល្លឺម៉ង់មាឌធំជាងអ្នកចាប់ខ្លាំង កាលពីសម័យសង្គ្រាមលោកលើកទី២ ។ រូបថតនេះ ថតក្នុងពេលប្រយុទ្ធគ្នានៅន័រម៉ង់ឌីបង្ហាញពលបាលទោ BOB RO-BERTS ដែលចាប់ខ្លួនទាហានអាល្លឺម៉ង់ម្នាក់មានមាឌធំជាងខ្លួនលើសលុប។រូបថតនេះ គឺទាហានមានកំពស់១,៥២ម៉ែត្រ ឈរទល់មុខទាហានមាឌយក្សអាល្លឺម៉ង់ត្រៀមឆែកឆេរទាហានមាឌយក្សនោះ ។



ទាហានមាឌតូចរបស់បារាំង ឆែកឆេរទាហានមាឌធំអាល្លឺម៉ង់

គឺអ្នកប្រវត្តិសាស្ត្រមួយរូប ដែលបានបញ្ជូនរូបថតនេះឱ្យ ដល់ពលបាលទោ ROBERTS ដែលពេលនេះ មានអាយុ៨៧ឆ្នាំ ក្នុងក្តីសង្ឃឹមថា អតីតយុទ្ធជនរូបនេះអាចស្គាល់ឈ្មោះរបស់ទាហានអាល្លឺម៉ង់មាឌធំនោះ ។ សម័យកាលនោះ លោក ROBERTS មានអាយុត្រឹមតែ២១ឆ្នាំ ដែលបំពេញភារកិច្ចប្រកបដោយគ្រោះថ្នាក់ ឆែកឆេរពួកទាហានសត្រូវដែលចាប់ខ្លួនបាន ហើយមានថ្ងៃមួយប៉ះចំលើទាហានមាឌយក្សអាល្លឺម៉ង់ ។ លោក ROBERTS រំលឹក អនុស្សាវរីយ៍និយាយប្រាប់គេ ពេលទទួលបាន រូបថតនេះថា ទាហានអាល្លឺម៉ង់រូបនោះ ជាទាហានមានមាឌខ្ពស់ជាងគេបំផុតរបស់ ប្រទេស គឺគេមានកំពស់ដល់ទៅ២,១៣ម៉ែត្រ ។ អតីតទាហានមាឌតូចដែលពេលនេះ រស់នៅជាមួយភរិយាឯទីក្រុង BOURNERMOUTH ប្រទេសអង់គ្លេស ក្រោយសង្គ្រាម គាត់មានកូន៤នាក់ចៅ១០នាក់ និងចៅទួត៦នាក់៕

# ប្រធានាធិបតី ដែលក្រជាងគេបំផុត នៅលើពិភពលោក

យោងតាមសារពត៌មាន Chosun កូរ៉េខាងត្បូង បានចុះផ្សាយនូវសេចក្តីប្រកាសស្តីពីហិរញ្ញវត្ថុ របស់រដ្ឋាភិបាលអ៊ុយរ៉ាហ្គាយ បានបង្ហាញឱ្យដឹងថា លោក Jose Mujica ប្រធានាធិបតីអ៊ុយរ៉ាហ្គាយបច្ចុប្បន្ន គឺជាប្រធានាធិបតីក្រ ជាងគេបំផុតនៅលើពិភពលោក។




លោក Jose Mujica និងរថយន្តធុនតូចរបស់គាត់

លោក Jose Mujica អាយុ៥៧ឆ្នាំជាមេដឹកនាំតែមួយគត់ដែលមិនមានទ្រព្យសម្បត្តិនៅក្នុងធនាគារ គ្មានបំណុល គ្មានផ្ទះសំបែង ហើយទ្រព្យសម្បត្តិសំខាន់បំផុតរបស់មេដឹកនាំអ៊ុយរ៉ាហ្គាយរូបនេះគឺជារថយន្តធុនតូចមួយប្រភេទBeetlesផលិតនៅឆ្នាំ១៩៨៧មានតំលៃ១៩០០ដុល្លារប៉ុណ្ណោះ។

លោក Jose Mujica ជាអតីតចលនាតស៊ូប្រឆាំងរដ្ឋាភិបាលផ្តាច់ការយោធាអ៊ុយរ៉ាហ្គាយ។កាលពីឆ្នាំកន្លងទៅលោកបានជាប់ឆ្នោតជាប្រធានាធិបតីហើយទើបទទួលតំណែងកាលពីខែមីនាឆ្នាំ២០១០នេះ។***(តទៅទំព័រទី២៩)***

# តុលាការដាក់កំហិតឲ្យមូរ សុខហួរ១០ថ្ងៃ ដើម្បីសងជំងឺចិត្តហ៊ុនសែន



លោកស្រី មូរ សុខហួរ និងលោកនាយករដ្ឋមន្ត្រី

សាលាដំបូងរាជធានីភ្នំពេញ បានដាក់កំហិតឲ្យតំណាងរាស្ត្របក្សប្រឆាំង លោកស្រី មូរ សុខហួរ ចំនួន ១០ថ្ងៃទៀត ចាប់ពីថ្ងៃព្រហស្បតិ៍ ទី១ ខែកក្កដានេះឲ្យបង់លុយជំងឺចិត្តលោកនាយករដ្ឋមន្ត្រីហ៊ុន សែន ចំនួន ៨ លានរៀលបើមិនដូច្នោះទេតុលាការនឹងអនុវត្តតាមច្បាប់។

ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ លោក ជា សុខ ហៀងបានបញ្ជាកាលពីថ្ងៃទី២៨ ខែមិថុនា ឲ្យលោកស្រី មូរ សុខហួរ យកប្រាក់ចំនួន ៨លានរៀលទៅតម្កល់នៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីទូទាត់ប្រាក់សំណងឲ្យលោក ហ៊ុន សែន ជាម្ចាស់បំណុល ដែលតុលាការបានកាត់ឲ្យលោកឈ្នះក្តីក្នុងករណីបរិហារកេរ្តិ៍។ លោក ជា សុខហៀង មិនបានពន្យល់លំអិតថា តុលាការនឹងចាត់វិធានការយ៉ាងដូចម្តេច ប្រសិនបើលោកស្រី មូរ សុខហួរ មិនបង់ប្រាក់ពិន័យទេ។ ប៉ុន្តែលោក សុខ រឿន ព្រះរាជអាជ្ញារងតុលាការក្រុងភ្នំពេញ បានមានប្រសាសន៍នៅថ្ងៃទី១ កក្កដា ថា តាមច្បាប់បើលោកស្រីមូរ សុខហួរ មិនបង់ប្រាក់ពិន័យតាមការសំរេចរបស់ចៅក្រមតុលាការទេនោះ លោកស្រីអាចជាប់ពន្ធនាគារ។ រតនាគាររាជធានីភ្នំពេញកាលពីថ្ងៃទី១៧ ខែមិថុនានេះ ក៏បានកំណត់ឲ្យលោកស្រី មូរ សុខហួរ បង់ប្រាក់ពិន័យ ៨លាន ៥សែនរៀល មិនឲ្យហួសពីថ្ងៃអាទិត្យទី៤ ខែកក្កដានេះទេ។ ករណីមិនព្រមបង់លុយ រតនាគារនឹងចាត់វិធានការតាមផ្លូវច្បាប់។

លោកស្រី មូរ សុខហួរ បច្ចុប្បន្នកំពុងស្នាក់នៅក្រៅប្រទេស ហើយគ្រោងនឹងវិលត្រឡប់មកកម្ពុជាវិញនៅថ្ងៃទី៥ ខែកក្កដានេះ។ នៅថ្ងៃសុក្រនេះ វិទ្យុអាស៊ីសេរីមិនអាចសុំការអត្ថាធិប្បាយពីលោកស្រីបានទេ ជុំវិញការដាក់កំហិតរបស់តុលាការនេះ។ ប៉ុន្តែលោកស្រីធ្លាប់បានសរសេរក្នុងសារអេឡិចត្រូនិកថា លោកស្រីមិនបង់ការផាកពិន័យទាំងអស់ដែលមានចំនួន ១៦លាន ៥សែនរៀលទេ ហើយថា លោកស្រីនឹងមិនរត់ចោលស្រុកឡើយ។

អង្គការសង្គមស៊ីវិល និងបក្សជំទាស់យល់ថា ប្រសិនបើលោកស្រី មូរ សុខហួរ ត្រូវគេចាប់ចូលពន្ធនាគារ លោកស្រីនឹងមានប្រជាប្រិយភាពកាន់តែខ្លាំង ដែលជានិមិត្តរូបនៃការទាមទារតុលាការឯករាជ្យនៅកម្ពុជា។

អ្នកនាំពាក្យរបស់គណបក្ស សម រង្ស៊ី លោក គឹម សួរភិរិទ្ធ មានប្រសាសន៍នៅថ្ងៃសុក្រ ទី២ ខែកក្កដា ថា គណបក្សនៅតែបន្តគោរពសេចក្តីសម្រេចចិត្តរបស់លោកស្រី មូរ សុខហួរ មិនបង់ប្រាក់សំណងក្នុងករណីបរិហារកេរ្តិ៍លោក ហ៊ុន សែន។ លោកថា គណបក្សគាំទ្រការដើរចូលគុករបស់លោកស្រី មូរ សុខហួរ ប្រយោជន៍ដើម្បីទាមទារប្រព័ន្ធតុលាការឯករាជ្យនៅកម្ពុជា។

នាយកអង្គការគណៈកម្មការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា លោក គល់ បញ្ញា មានប្រសាសន៍នៅថ្ងៃសុក្រនេះដែរថា តុលាការកម្ពុជាមិនត្រូវចាប់លោកស្រី មូរ សុខហួរ ដាក់ពន្ធនាគារ ដោយសារតែលោកស្រីមិនព្រមបង់លុយផាកពិន័យរបស់តុលាការទេ ពីព្រោះករណីនេះមិនមែនជាបទព្រហ្មទណ្ឌ។ លោកថា គួរមានការសម្របសម្រួលនយោបាយណាមួយដើម្បីបញ្ចប់ករណីនេះ ពីព្រោះបើបន្តទាំងលោកស្រី មូរ សុខហួរ និងរដ្ឋាភិបាលចាញ់ទាំងពីរ ដោយសារលោកស្រីអាចជាប់គុក ហើយរដ្ឋាភិបាលអាប់កេរ្តិ៍ឈ្មោះក្នុងការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

(តទៅទំព័រទី២៩)

# ជំនួបកំពូល G8 ៖ អាមេរិកនិងអឺរ៉ុបខ្វែងគំនិតគ្នាលើនយោបាយសេដ្ឋកិច្ច

*ជំនួបកំពូលក្រុមប្រទេស G8 នឹង បើកធ្វើនៅថ្ងៃសុក្រ ទី២៥ មិថុនា ២០១០នេះ មុននឹងឈានទៅបើកជំនួបកំពូល20នៅថ្ងៃសៅរ៍និងថ្ងៃអាទិត្យ។ ប្រធានបទចម្បង ក្នុងជំនួបកំពូល G8 នេះ គឺនឹងផ្តោតទៅលើភាពចម្រូងចម្រាស់គ្នា រវាងអាមេរិក និងសហភាពអឺរ៉ុប ជុំវិញការកាត់បន្ថយបំណុលសាធារណៈ។* ចាប់តាំងពីផ្ទុះវិបត្តិនៅប្រទេសក្រិកមក បណ្តាប្រទេសសមាជិកសហភាពអឺរ៉ុប បាននាំគ្នាដាក់ចេញនូវនយោបាយថ្មីមួយ គឺធ្វើយ៉ាងណាកាត់បន្ថយការចំណាយ ដើម្បីកាត់បន្ថយបំណុលរបស់រដ្ឋ។ គោលដៅ គឺដើម្បីស្តារទំនុកចិត្តពីសំណាក់អ្នកវិនិយោគ ចៀសវាងការរីករាលដាលនៃវិបត្តិទៅបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់អឺរ៉ូប។ ក៏ប៉ុន្តែរដ្ឋាភិបាលអាមេរិកបានសម្តែងនូវការមិនពេញចិត្តចំពោះនយោបាយរបស់សហភាពអឺរ៉ុបនេះ។ មន្ត្រីរដ្ឋាភិបាលអាមេរិក រួមទាំងលោកប្រធានាធិបតីអូបាម៉ាផងយល់ថា នៅក្នុងពេលដែលពិភពលោកកំពុងតែខិតខំងើបចេញពីវិបត្តិសេដ្ឋកិច្ច គេគួរតែនាំគ្នាផ្តោតជាអាទិភាពលើការជំរុញកំណើនសេដ្ឋកិច្ច។ ប្រសិនបើគ្រប់ប្រទេសនាំគ្នាកាត់បន្ថយការចំណាយវានឹងនាំឲ្យកំណើនសេដ្ឋកិច្ចត្រូវរាំងស្ទះ ហើយគេនឹងមិនអាចងើបចេញពីវិបត្តិរួចនោះទេ។ ការខ្វែងគំនិតគ្នានេះ ប្រាកដជានឹងក្លាយទៅជាការជជែកតស៊ូមតិគ្នា នៅក្នុងជំនួបកំពូលក្រុមG8( សហរដ្ឋអាមេរិក,អាឡឺម៉ង់, អង់គ្លេស, បារាំង, អ៊ីតាលី, ជប៉ុន, កាណាដា និងរុស្ស៊ី) នៅថ្ងៃសុក្រនេះ។




ជំនួបកំពូល G8/G20 នៅកាណាដា ពីថ្ងៃសុក្រទី២៥ ដល់ថ្ងៃអាទិត្យ ទី២៧ មិថុនា ២០១០

នៅមុនពេលបើកជំនួបកំពូល លោកអូបាម៉ាបានទូរស័ព្ទទៅកាន់នាយករដ្ឋមន្ត្រីអង់គ្លេស និងប្រមុខរដ្ឋាភិបាលអាឡឺម៉ង់ ដើម្បីសម្តែងនូវកង្វល់របស់លោកចំពោះនយោបាយសន្សំសំចៃរបស់អឺរ៉ុប។ក៏ប៉ុន្តែ ប្រមុខរដ្ឋាភិបាលអាឡឺម៉ង់ លោកស្រី អង់ហ្គេឡា មែរកិល (Angela Merkel) បានអះអាងថា ការកាត់បន្ថយការចំណាយនៅអឺរ៉ុបនឹងមិនធ្វើឲ្យរាំងស្ទះដល់កំណើនសេដ្ឋកិច្ច ដូចការព្រួយបារម្ភរបស់អាមេរិកនោះទេ។កាលពីយប់ថ្ងៃព្រហស្បតិ៍នេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចអាមេរិកបានព្យាយាមបន្ធូរបន្ថយភាពតានតឹងបន្តិច ដោយបានលើកឡើងថាថ្វីដ្បិតតែអាមេរិក និងសហភាពអឺរ៉ុបមានជំហរខុសគ្នាក៏ពិតមែន ក៏ប៉ុន្តែគោលដៅគឺមានដូចគ្នា។ ដូច្នេះលោកជឿថានៅទីបំផុតអាមេរិក និងអឺរ៉ុប ប្រាកដជាអាចស្វែងរកជំហររួមគ្នាមួយ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចអាមេរិកបានទទួលស្គាល់ថាការកាត់បន្ថយបំណុលសាធារណៈដើម្បីស្តារទំនុកចិត្តពីសំណាក់អ្នកវិនិយោគគឺជារឿងចាំបាច់ ក៏ប៉ុន្តែ អឺរ៉ុបគួរតែថ្លឹងថ្លែងគ្នាឲ្យបានស្មើធ្វើយ៉ាងណាកុំឲ្យការកាត់បន្ថយចំណាយមានចំនួនច្រើនហួសហេតុពេក ហួតដល់ប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច។

មិនថាតែរដ្ឋាភិបាលទេ ដែលខ្វែងគំនិតគ្នា។ សូម្បីតែសេដ្ឋវិទូក៏មានគំនិតផ្ទុយគ្នាដែរ អំពីការកាត់បន្ថយការចំណាយសាធារណៈនេះ។ អ្នកខ្លះយល់ថា គេគួរតែរង់ចាំឲ្យស្ថានភាពសេដ្ឋកិច្ចចេញផុតពីវិបត្តិឲ្យបានស្រួលបួល និងមានស្ថិរភាពសិន មុននឹងចាប់ផ្តើមធ្វើការកាត់បន្ថយបំណុលសាធារណៈ។ អ្នកខ្លះទៀតយល់ថា គេត្រូវតែចាប់ផ្តើមកាត់បន្ថយបំណុលពីពេលនេះទៅ ដើម្បីចៀសវាងកុំឲ្យអ្នកវិនិយោគបាត់បង់ទំនុកចិត្ត ដែលជាដើមហេតុនាំឲ្យរាំងស្ទះដល់កំណើនសេដ្ឋកិច្ច៕

# ខ្ញីមានគុណប្រយោជន៍ជួយបំបាត់អាការចុករោយសាច់ដុំ



សាស្ត្រាចារ្យនៃមហាវិទ្យាល័យចចជៀ សហរដ្ឋអាមេរិកបានធ្វើការសិក្សាស្រាវជ្រាវរកឃើញថា ខ្ញីមានគុណប្រយោជន៍ដល់សាច់ដុំដែលចុករោយក្រោយពីធ្វើការហាត់ប្រាណ និង ផ្តល់លទ្ធផលល្អជាងថ្នាំបំបាត់អាការៈឈឺចាប់ផ្សេងៗ។ សាស្ត្រាចារ្យប៉ាទ្រិកអូខុនណ័រ ប្រធានក្រុមអ្នកស្រាវជ្រាវបានបង្ហើបឱ្យដឹងថាខ្ញីអាចប្រើប្រាស់ធ្វើជាឱសថបុរាណប្រចាំនៅផ្ទះសំរាប់ព្យាបាលជំងឺតម្កាត់ផ្សេងៗតាំងពីក្អក រហូតដល់ការចុកពោះដោយមានរយៈពេលជាយូរឆ្នាំមកហើយ ។ សំរាប់ការសិក្សាស្រាវជ្រាវក្នុងអំឡុងពេលចុងក្រោយនេះមានការប្រទះឃើញថា វាអាចជួយបំបាត់ការឈឺចុកចាប់លើសាច់ដុំបានល្អផងដែរ ។

តាមលទ្ធផលស្រាវជ្រាវបានធ្វើឱ្យគេមានជំនឿថា វាមានគុណប្រយោជន៍លើសថ្នាំបំបាត់ការចុកចាប់ជាច្រើនប្រភេទទៀត។ មនុស្សជាច្រើននាក់ដែលធ្លាប់បានទទួលការចុករោយក្នុងអំឡុងពេលកន្លងមករមែងមានការត្រេកអរ និងយល់ព្រមទទួលយកអ្វីៗគ្រប់យ៉ាង ដែលអាចជួយបំបាត់ការឈឺចាប់ក្នុងរាងកាយ ជាពិសេសគឺខ្ញីដែលជាអាហារដ៏ឆ្ងាញ់ពិសារបស់មនុស្សទូទៅ ។

នៅក្នុងលទ្ធផលសិក្សាស្រាវជ្រាវបង្ហាញឱ្យឃើញថា ខ្ញីអាចជួយកាត់បន្ថយការឈឺចុករោយដែលកើតឡើងតាមរយៈការហាត់ប្រាណបានដល់ទៅ២៥%និងធ្វើឱ្យគេដឹងថា វាមានសារជាតុគីមីដែលមានប្រយោជន៍ប្រៀបដូចថ្នាំបំបាត់ការឈឺចាប់ដូចជាថ្នាំ អាស្ពីរីន និងព្យាបាលអាការៈរលាកជាដើម ៕

# ផលប្រយោជន៍របស់អង្ករសរីរាង្គ



រាជធានីភ្នំពេញ៖ អង្ករសរីរាង្គជាប្រភេទអង្ករដែលអតិថិជនទូទៅច្រើននិយមហៅថា អង្ករធម្មជាតិ ឬអង្ករដែលផលិត វេច ខ្ចប់ និងស្តុកមិនប្រើប្រាស់សារជាតុគីមី និងថ្នាំពុល។បើតាមលោកគាមមករាឌី នាយកកម្មវិធីសុខភាព និងបរិស្ថានរបស់អង្គការសេដាកបានមានប្រសាសន៍ថាអង្ករសរីរាង្គ គឺជាប្រភេទអង្ករដែលផលិតគោរពទៅតាមបទដ្ឋានស្តង់ដាកសិកម្មសរីរាង្គច្បាស់លាស់ ដែលមិនប្រើប្រាស់សារជាតុគីមីសំយោគ និងមិនប្រើពូជកែច្នៃហ្សែន។

លោកបានបញ្ជាក់ទៀតថា យើងអាចនិយាយបានថា អង្ករយើងជាប្រភេទអង្ករសរីរាង្គឬអង្ករធម្មជាតិ លុះត្រាតែមានក្រុមហ៊ុន ឬស្ថាបន័ណាមួយធ្វើការត្រួតពិនិត្យ និងបញ្ជាក់ថាផលិតផលអង្ករនេះបានអនុវត្តតាមស្តង់ដាកសិកម្មសរីរាង្គ។ លោកបានបន្ថែមទៀតថា សំរាប់ស្តង់ដាកសិកម្មសរីរាង្គសំខាន់ៗមាន៣ ប្រភេទស្តង់ដាគឺស្តង់ដាកសិកម្មសរីរាង្គរបស់អឺរ៉ុបស្តង់ដាសរីរាង្គរបស់អាមេរិកនិងស្តង់ដាសរីរាង្គរបស់ជប៉ុន។ ចំពោះស្តង់ដាកសិកម្មសរីរាង្គរបស់អង្គការសេដាកគឺបានបង្កើតឡើងដោយយកមូលដ្ឋានពីស្តង់ដាសរីរាង្គរបស់អឺរ៉ុប........... *(តទៅទំព័រទី២៨)*

*(តមកពីទំព័រទី២១)*( Prime Minister ) ប្រធានាធិបតី( President ) អធិការបតី ( Chancellor ) ឬអគ្គលេខាធិការ ( General Secretary ) ជាដើម ដែលជាសរុបទៅបុគ្គលទាំង នោះគេហៅថា អ្នកដឹកនាំ ( leader )។

ដោយមិនចង់ដើរជាន់ដានចាស់ទើបកាតព្វកិច្ច មួយចំនួន ជាតួយ៉ាងសិទ្ធ , អំណាច និងកាតព្វកិច្ចនៃការសម្រេចថាអ្នកណាខុស អ្នកណាត្រូវ និងកំណត់ថាអ្នកណាមានទោស ឬ មិនមានទោស ពោលគឺការវែកញែករកយុត្តិធម៌( Rights to provide justice ) នោះត្រូវបានដកហូតចេញពីនាយករដ្ឋមន្ត្រី ប្រធានាធិបតី អធិការបតី ឬអគ្គលេខាធិការជាដើមនោះទៀត ហើយប្រគល់ទៅអោយបុគ្គលម្នាក់ទៀត ដែលគេហៅថាចៅក្រមឬតុលាការ( Judge )ដែលមានន័យថា ជាអ្នកអារកាត់ដោយ មានការថ្លឹងថ្លែងអោយស្មើភាព ឬ យុត្តិធម៌ដោយយកច្បាប់ជាកត្តាវាស់វែង( Balanced Judge )។

ទោះជាសម័យបច្ចុប្បន្ន បុគ្គលជាចៅក្រម ឬ តុលាការនោះ មានលក្ខន្តិកៈការងារតឹងរឹងយ៉ាងណាក្តី ក៏ជារឿយៗគេឮការឧទ្ទានឡើងថា អយុត្តិធម៌ណាស់ ! តុលាការលំអៀង....! ˝

នៅក្នុងគម្ពីរសុត្តន្តបិដកទីឃនិកាយ បាដិកវគ្គ មានកត់ត្រាអំពីគោលធម៌សម្រាប់បុគ្គល ដែលមាននាទីជាអ្នកសម្រេចសេចក្តី ឬ វិនិច្ឆ័យក្តី ជៀសវាងអោយខាងតែបាន។ ដូច្នេះពេលនេះបញ្ហានៅត្រង់ថា តើគេព្រមអនុវត្តដែរឬអត់។ ព្រះពុទ្ធមិនមែនជាអ្នកអង្កេតការណ៍នៅក្នុងតុលាការទេ ប៉ុន្តែព្រះអង្គទ្រង់បានជ្រាបបញ្ហានេះយ៉ាងច្បាស់ ហើយបានរកឃើញដំណោះស្រាយពីឫសគល់នៃបញ្ហានេះទៀតផង។ព្រះពុទ្ធបានហៅបញ្ហានេះថា អគតិៈ

ពោលគឺការលំអៀង ហើយវាមានឫសគល់ ឬ ប្រភព ៤ យ៉ាងគឺៈ

**១-លំអៀងឬអគតិព្រោះស្រលាញ់**( ឆន្ទាគតិ ) Prejudice of love or desire: partiality ): បុគ្គលជា សាច់ញាតិ ជាគ្រួសារ ជាជនជាទីស្រលាញ់របស់ខ្លួន ជាបក្ខពួករបស់ខ្លួន ឬត្រូវគេសូកប៉ាន់ដោយការផ្តល់អោយនូវប្រយោជន៍អ្វីមួយជាដើម នៅពេលដែលបុគ្គលទាំងនោះប្រព្រឹត្តខុសពេលត្រូវគេប្តឹងក៏តាំងមើលរំលងទោសានុទោសនោះៗ ហើយរំលប់រំលាយ រំសាយកំហុសទាំងនោះរួចហើយក៏សម្រេចអោយបុគ្គលទាំងនោះរួចខ្លួន មួយវិញសោតបុគ្គលទាំងនោះប្រព្រឹត្តខុសមានទំហំធំធេងដូចជាវាយដំធ្វើបាបអ្នកទន់ខ្សោយ រឹបអូសទ្រព្យសម្បត្តិគេ បំពារបំពានលើអ្នកដទៃ ចាប់រំលោភ ឬកាប់សំលាប់គេជាដើម នៅពេលមានភស្តុតាង និងសាក្សីជាក់ស្តែងពេក ក៏បែរជាអោយត្រឹមតែសារភាពកំហុស សុំទោសជាដើមក៏ចប់ទៅ ។ តើភាគីជនរងគ្រោះអាចទទួលយកបានទេ? សម្រេកអយុត្តិធម៌ប្រាកដជាលាន់ឮឡើង។

**២- លំអៀង ឬ អគតិព្រោះ ស្អប់ ឬ ខឹង** ( ទោសាគតិ = Prejudice of hatred or enmity ): ដោយហេតុបុគ្គលនោះ ក្រុមនោះ ជាមនុស្ស ឬជាក្រុមគូបដិបក្ខ ឬមាននិន្នាការផ្សេងពីក្រុមខ្លួន, ជាមនុស្ស ឬ ក្រុមដែលខ្លួនមិនពេញចិត្ត ឬ ធ្លាប់មានគំនុំជាមួយខ្លួនជាដើម ។ ពេលបុគ្គលនោះ ក្រុមនោះមានបញ្ហាក្តីក្តាំក៏កាត់ក្តីអោយចាញ់ ឬបើមានកំហុសតិចតួច ក៏ ធ្វើអោយមានទោសធ្ងន់ជាដើម ។

**៣-លំអៀងឬអគតិព្រោះវង្វេងឬ ល្ងង់ខ្លៅ** ( មោហាគតិ= Prejudice of delusion or stupidity )ដោយហេតុខ្វះការប្រុងប្រយ័ត្នទើបទទួលបានភស្តុតាង និង សាក្សីដែលគេក្លែងបំភ័ន្ត ព័ត៌មានមិនពិតទើបកាត់ក្តីខុស។ ភាពមិនឆ្លៀវឆ្លាស ក្នុងកិច្ចអង្កេតនិងថ្លឹងថ្លែងហេតុការណ៍ ក៏មិនអាចវិនិច្ឆ័យក្តីអោយបានសុក្រឹត ។....................... *(តទៅទំព័រទី២៨)*

# ហាងមាសមេគង្គ

# 湄江 MEKONG JEWELRY 珠寶



- **មានលក់មាសនិងពេជ្រគ្រប់ប្រភេទ**
- មានលក់គុជនិងត្បូងពេជ្រជាច្រើនសម្រាប់ធ្វើជាខ្សែក, ខ្សែដៃ, ក្រវិលនិងចិញ្ចៀន។ល។
- ទទួលរចនាគ្រឿងអលង្ការគ្រប់មុខគ្រប់ម៉ូដតាមការនិយមចូលចិត្តបែបបុរាណឬសម័យ។
- ទទួលជួសជុលគ្រឿងអលង្ការភ្លាមៗ !!!

សូមស្វាគមន៍អតិថិជនគ្រប់ទិសទី !!!

- **All Kinds of Diamonds & golds**
- COUNTLESS OF STYLES AVAILABLE FOR RINGS, NECKLACE, BRACELETS, ETC.
- WE ACCOMODATE ANY DESIGN THAT BEST SUITS YOUR INTERESTS.
- WE ARE MORE THAN HAPPY TO FIX OR REDESIGN YOUR PREOWNED JEWELRY.
- A VISIT TO OUR STORE WILL GUARANTEE YOUR SATISFACTIONS.

ADDRESS:
1954 ABORN ROAD
SAN JOSE, CA 95121

KIM
TEL: (408) 238-3377
FAX: (408) 238-2601

## ក្រុមហ៊ុនលក់សំបុត្រយន្តហោះTravel Rose

- មានលក់សំបុត្រយន្តហោះក្នុងនិងក្រៅប្រទេស
- មានទទួលធ្វើទិដ្ឋាការទៅ អាស៊ី, អឺរុប, អូស្ត្រាលី និងប្រទេសផ្សេងៗនៅជុំវិញពិភពលោក។
- មានទទួលធ្វើលិខិតឆ្លងដែន
- **Airline Ticket, Re-entry Permit, Visa, Passport**

សូមអញ្ជើញទំនាក់ទំនងមកក្រុមហ៊ុនយើងខ្ញុំដោយមេត្រីភាព តាមអាសយដ្ឋានដូចខាងក្រោម

| Travel Rose<br>Travel &Tour<br>ANH(THANH)V0 | 639 Tully Road Suite<br>San Jose, CA 95111<br>Tel: (408) 971-4530 |
|---|---|







*(តមកពីទំព័រទី២៦)* **៤- លំអៀង ឬ អគតិព្រោះភ័យខ្លាច** ( ភយាគតិ Prejudice of fear):បុគ្គល(ឬ សាច់ញាតិ បក្សពួករបស់បុគ្គល ) ដែលមានឋានៈ បុណ្យស័ក្តឬទ្រព្យសម្បត្តិជាដើម ដឹងថាបុគ្គលទាំងនោះប្រព្រឹត្តល្មើសហើយ ប៉ុន្តែនៅតែមិនហ៊ានផ្តន្ទាទោសទៅតាមនិយាយច្បាប់ដែលបានកំណត់រួចហើយ ដោយហេតុតែខ្លាចឋានៈបុណ្យស័ក្តបុគ្គលនោះជាដើម។

បុគ្គលជាអ្នកកាន់ច្បាប់ឬចៅក្រម តុលាការត្រូវតែជៀសវាងអោយខាងតែបាននូវអគតិទាំង៤នេះ ទើបអាចធានាបានថា យុត្តិធម៌(Justice)នឹងប្រព្រឹត្តទៅចំពោះមនុស្សទូទៅ ។ ព្រះពុទ្ធបានបង្រៀនថា គេអាចលះបង់ទ្រព្យសម្បត្តិ ដើម្បីរក្សាអវយវៈ លះបង់អវយវៈ ដើម្បីរក្សាជីវិត ប៉ុន្តែក្នុងករណីខានមិនបាន សុខចិត្តលះបង់ជីវិត (ឬមុខតំណែង)ដើម្បីរក្សាធម៌។ធម៌គឺអ្វីដែលពិតមិនលំអៀងឬយុត្តិធម៌នេះឯង។

ចំណែកអ្នកដឹកនាំ ត្រូវតែប្រយ័ត្នអោយមែនទែនកុំអោយធ្លោយខ្លួនចូលទៅក្នុងអគតិណាមួយជាដាច់ខាត។ ជាអ្នកដឹកនាំគេ ជារឿយៗរមែងមានមនុស្សប្លម អែបអប វណែបវណប ចាក់ចេក ចាក់ស្ករ ញុះញង់ ក្លែងបន្លំការពិត ( ជាពិសេស មនុស្សនៅក្បែរខ្លួន ) ដែលប្រការទាំងនេះឯង ធ្វើអោយអ្នកដឹកនាំក្លាយជាជនអគតិ ខ្វះយុត្តិធម៌ ខ្វះគុណធម៌ដោយមិនដឹងខ្លួនឬ ដោយចេតនាក៏សឹងមាន៕

---

*(តមកពីទំព័រទី២០)* អារម្មណ៍ស្មុគស្មាញណាស់មិនចង់ឮសំឡេងរំខានទេ ។ រៀបបាយឱ្យប្តីនៅជជែកជាមួយប្តីកុំដើរទៅណាឱ្យសោះ... ការនៅក្បែរប្តី និងរៀបចំសណ្តាប់ធ្នាប់ក្នុងផ្ទះ គឺជាការលើកកម្លាំងចិត្តដល់ប្តីធ្វើឱ្យប្តីជ្រះថ្លាក្នុងអារម្មណ៍ខិតខំធ្វើការដើម្បីគ្រួសារបានល្អប្រសើរកាន់តែខ្លាំង ៕

---

*(តមកពីទំព័រទី២៥)* និងអាមេរិក ហើយធ្វើការកែសំរួលខ្លះទៅតាមស្ថានភាពរបស់កសិករខ្មែរយើង។លោកឡុងសេងហ៊ង នាយកសហគ្រាសសេដាក បានមានប្រសាសន៍ឱ្យដឹងថា អង្ករសរីរាង្គដែលដាក់លក់នៅតាមផ្សារអង្គការសេដាក គឺមានការត្រួតពិនិត្យនិងបញ្ជាក់គុណភាពច្បាស់លាស់ពីអង្គការសេដាក។ លោកបានបញ្ជាក់បន្ថែមថាសហគ្រាសសេដាកបានធ្វើកិច្ចសន្យាទិញស្រូវពីសហពន្ធ័ផលិតស្រូវសេរីរាង្គ ដែលមានការរៀបចំប្រពន្ធ័ត្រួតពិនិត្យផ្ទៃក្នុងច្បាស់លាស់ ហើយដែលធានាគោរពតាមស្តង់ដាកសិកម្ម ព្រមទាំងមានការបញ្ជាក់គុណភាពបន្ថែមពីអង្គការសេដាក។ ចំពោះការនាំចេញយកទៅលក់នៅទីផ្សារបរទេស សហគ្រាសសេដាកបាន ជួលក្រុមហ៊ុនបរទេស BCS ពីប្រទេសអាល្លឺម៉ង់មកធ្វើការបញ្ជាក់បន្ថែម។

លោកមាស សៅ ប្រធានសហគមន៍ផលិតស្រូវសេរីរាង្គនៅឃុំស្វាយចចឹប ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដែលបានលក់ស្រូវសេរីរាង្គឱ្យសហគ្រាសសេដាកនោះបានមានប្រសាសន៍ថា សហគមន៍របស់លោកបានលក់ស្រូវសេរីរាង្គអោយសហគ្រាសសេដាកអស់រយៈពេល៣ឆ្នាំកន្លងមកហើយដែលនៅចុងឆ្នាំ២០០៩នេះ សហគមន៍លោកបានលក់ស្រូវប្រមាណ១៥០តោនមកឱ្យសហគ្រាសសេដាក។ នៅពេលដែលសួរថា តើលោកមានការទុកចិត្តកំរិតណាចំពោះសមាជិករបស់សហគមន៍របស់លោកថាពិតជាបានអនុវត្តទៅតាមស្តង់ដាកសិកម្មសរីរាង្គពិតប្រាកដ ?លោកមាស សៅ មានប្រសាសន៍ថា សហគមន៍ខ្ញុំមានការធានាច្បាស់លាស់ថា គ្រប់សមាជិកពិតជាបានអនុវត្តតាមស្តង់ដាកសិកម្មសរីរាង្គមិនមានការលួចបន្លំប្រើប្រាស់ជីគីមី ឬថ្នាំពុលឡើយ ។ លោកបានបន្តថា សមាជិកទាំងអស់បានទទួលការបណ្តុះបណ្តាលនិងណែនាំជារៀងរាល់ឆ្នាំ ហើយសហគមន៍មានការរៀបចំប្រពន្ធ័ត្រួតពិនិត្យផ្ទៃក្នុង ដើម្បីតាមដានការអនុវត្តបច្ចេកទេសនិងការផលិតជីធម្មជាតិរបស់សមាជិក។ទន្ទឹមនេះអង្គការ......... *(តទៅទំព័រទី២៩)*

*(តមកពីទំព័រទី២៨)* សេដាកមានការត្រួតពិនិត្យបន្ថែមលើអ្វីដែលសមាគមន៍បានអនុវត្ត។ លោកមាស សៅ បាន សង្កត់ធ្ងន់ថា និយាយរួមសហគមន៍បានបណ្តុះដល់សមាជិកអោយមានភាពស្មោះត្រង់ជាមួយទីផ្សារដោយពន្យល់ថាប្រសិនបើទីផ្សារមានបញ្ហានោះសហគមន៍របស់យើងក៏ជួបប្រទះនូវបញ្ហាផងដែរ។

អង្ករសរីរាង្គត្រូវបានអង្គការសេដាកដាក់លក់ចាប់តាំងពីឆ្នាំ២០០៤មកម្ល៉េះ ដែលបរិមាណស្រូវលក់ដំបូងមានចំនួនប្រមាណ១០តោន ហើយនៅឆ្នាំ២០១០នេះអង្គការសេដាកបានប្រមូលទិញស្រូវពីសហគមន៍ចំនួនប្រមាណ១៥០០តោន នៅក្នុង៧ខេត្តដែលមានសមាជិកផលិតជិត២០០០គ្រួសារ សំរាប់ការលក់នៅទីផ្សារក្នុងស្រុក និងការនាំ ចេញខ្លះ។

នាយកសហគ្រាសសេដាកលោក ឡាង សេងហ៊ង មានប្រសាសន៍ថាការគាំទ្ររបស់អតិថិជនចំពោះអង្ករសរីរាង្គមានការកើនឡើងជារៀងរាល់ឆ្នាំ ដោយពួកគាត់យល់ឃើញថាការទិញអង្ករសរីរាង្គយកទៅបរិភោគវាមិនត្រឹមតែជួយដល់សុខភាពរបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែពួកគាត់បានចូលរួមចំណែកជួយជំរុញអោយប្រទេសកម្ពុជាក្លាយជាប្រទេសមួយដែលទឹកដីនិងចំណីអាហារគ្មានជាតិគីមី៕

---

*(តមកពីទំព័រទី២៣)* អ្នកនាំពាក្យរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លោក ផៃ ស៊ីផាន មានប្រសាសន៍នៅថ្ងៃសុក្រថា លោកស្រី មូរ សុខហួរ គួរគោរពសេចក្តីសម្រេចរបស់តុលាការ ដើម្បីធ្វើឲ្យនីតិរដ្ឋនៅកម្ពុជាមានលក្ខណៈប្រសើរ។ លោកថា ករណីរបស់លោកស្រី មូរ សុខហួរ ជាករណីដោយឡែក មិនតំណាងឲ្យប្រជាជនកម្ពុជាទាំងមូល ក្នុងការទទួលបានប្រព័ន្ធយុត្តិធម៌ឯករាជ និងប្រសិទ្ធភាពទេ។

អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ លោក ស៊ូយ៉ា ស៊ូប៊ែឌី (Surya Subedi) បានរិះគន់កាលពីថ្ងៃទី១៧ ខែមិថុនា បន្ទាប់ពីបញ្ចប់បេសកកម្មចំនួន ១០ថ្ងៃរបស់លោកថា ប្រព័ន្ធតុលាការនៅកម្ពុជា កំពុងជួបប្រទះនឹងការលំបាកជាច្រើន ក្នុងការផ្តល់យុត្តិធម៌ជូនប្រជាជននៃប្រទេសនេះ ជាពិសេសប្រជាជនក្រីក្រ និងប្រជាជនដែលគេមិនសូវគិតគូរដល់។ការខ្វះខាតក្នុងប្រព័ន្ធយុត្តិធម៌នេះបានធ្វើឲ្យប្រជាពលរដ្ឋបាត់ជំនឿក្នុងប្រព័ន្ធយុត្តិធម៌៕ *ប្រភព RFA*

---

*(តមកពីទំព័រទី១៨)* ដឹងទៀតថាពួកគាត់បានត្រឡប់ទៅផ្ទះវិញបន្ទាប់ពីមន្ត្រីការិយាល័យគណៈកម្មាធិការជនជាតិ និងតំបន់ភ្នំ ប្រចាំក្រុងគិនជើ ឬព្រៃកប្បាស្សី បានបដិសេធន៍ថា ពុំមានមន្ត្រីធ្វើការឡើយ។មន្ត្រីសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពបានឲ្យដឹងថា កន្លងមកពលរដ្ឋខ្មែរកម្ពុជាក្រោមដែលចូលរួមតវ៉ានោះ ចំនួន៤ខេត្ត គឺខេត្តមាត់ជ្រូក ខេត្តឃ្លាំង ខេត្តព្រះត្រពាំង និងខេត្តក្រមួនស អតីតទឹកដីខ្មែរកម្ពុជា ដែលបច្ចុប្បន្នគ្រប់គ្រង ដោយប្រទេសវៀតណាមសរុបប្រមាណជា ៥០០គ្រួសារ បានរួមគ្នាតវ៉ាពីបញ្ហាដីធ្លីនេះ។ បន្ទាប់មកនៅដើមឆ្នាំ២០០៩ ក៏មានការចាប់ខ្លួនពលរដ្ឋម្នាក់ដាក់ពន្ធនាគារ រីឯសកម្មភាពនៃការតវ៉ា ក៏បានថមថយរហូតមកដល់ថ្ងៃនេះ៕ *ប្រភព RFA*

---

*(តមកពីទំព័រទី២២)* ពេលក្លាយជាមេដឹកនាំកំពូលប្រទេសអ៊ុយរ៉ាហ្គាយ មេដឹកនាំJose Mujicaនៅតែរក្សាអាកប្បកិរិយាដូចមុនដដែល។ហើយបដិសេធទៅស្នាក់នៅក្នុងវិមានប្រធានាធិបតីទៀតផង។ បច្ចុប្បន្នលោកប្រធានាធិបតីរូបនេះកំពុងរស់នៅជាមួយភរិយាដែលជាអ្នកតំណាងរាស្ត្ររស់នៅក្នុងផ្ទះតូចមួយ ក្នុងទីក្រុងម៉ុងតេវីដេអូជាកម្មសិទ្ធិរបស់ភរិយា។ ប្រាក់ខែរបស់លោកចំនួន១១.០០០ដុល្លារ តែលោកមិនបានចាយប្រាក់ខែទាំងអស់នោះទេ ដោយចំណាយ១ភាគ៥ទៅឱ្យមូលនិធិគណៈបក្សរបស់លោក។ ក្រៅពីនោះលោកផ្តល់ឱ្យមូលនិធិរដ្ឋសំរាប់កសាងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗឱ្យតំបន់ដែលប្រជាជនក្រីក្រ៕

# ស្ពាយកេរ្តិ៍ចាស់

ស្ពាយកេរ្តិ៍បុរាណលោកខំសាង ទុកជាតំណាងវប្បធម៌ខ្មែរ
ឥឡូវរេចរឹលទៅហែរៗ ព្រោះតែស្រុកទេសកើតចម្បាំង។
កេរ្តិ៍ខ្លះវិនាសដោយធម្មជាតិ ដោយធាតុអាកាសប្រែប្រួលខ្លាំង
កេរ្តិ៍ខ្លះវិនាសដោយចោរខ្មាំង វាតាំងជីកគាស់កាយរលើង។
ស្ពាយជនចិត្តចោរសោគំនិត គួចចិត្តតែលួចតាមទំនើង
បាត់ជាតិបាត់សាសន៍ធ្វើមិនដឹង គេប្រឹងតែលួចលក់យកប្រាក់។
ស្ពាយកេរ្តិ៍ដូនតាការខ្វះថៃ យូរឆ្នាំយូរខែក្តៅត្រជាក់
នៅដោយកន្លែងគ្មានធ្វើថ្នាក់ ធូលីហុយដាក់កណ្តុរកាត់។
ស្ពាយបាត់គតិប្រជាប្រិយ ទំនៀមប្រពៃមានច្រើនក្តាត់
រស់រៀនតំណ តតាមមាត់ ចាស់គាត់ចេះចាំតាមសំនួន។
ឥឡូវចាស់ស្លាប់បាត់ស្ទើរអស់ យកទាំងរបស់ប្រចាំខ្លួន
ចំណេះចំណាំគ្មានក្នុងក្បួន ចាស់ចាំដោយខ្លួនមិនបានចារ។
ស្ពាយភ្លេចចំរៀងសៀងពិរោះ ស្ពាយព្រោះរបាំល្បែងប្រជា
ក្មេងក្រោយមិនស្គាល់ទាល់ប្រាជ្ញា យកស្បែកពាលាមកជំនួស។
ស្ពាយព្រៃព្រឹក្សាលតាវល្លិ ឈើល្អបូរាណបានដាក់ឈ្មោះ
ប្រភេទផ្សេងៗគ្មានចន្លោះ ស្ពាយបាត់ដើមអស់សល់តែនាម។
ស្ពាយឈើស្ពាយព្រៃចាស់លោកដាំ ទុកជាដំណាំក្នុងអារាម
កាលមានចាស់នៅចាស់លោកហាម ពេលអត់ចាស់ភ្លាមក្មេងបានដៃ។
ស្ពាយមិនបានដាំចាំតែកាប់ ស្ពាយចាប់ច្រើនជាងចិញ្ចឹមត្រី
ទឹកសាបសមុទ្រមិនយូរថ្លៃ គង់ក្សំយផុតពូជមិនសល់ដាន។
ឯឥឡូវរតនៈមានតំលៃ ក៏គង់មានថ្ងៃអន្តរធាន
ព្រៃក្លាយជាវាលរហោស្ថាន គួរខ្មែរគិតអានគ្រប់អាត្មា។
អស់ព្រៃអស់សត្វបាត់ទាំងទឹក ខ្វះហូបល្ងាចព្រឹកខ្វះមន្ឆា
ព្រៃទន្លេស្ទឹងបឹងជលសា ប្រែជារីងស្រកខកខានខែង។
ស្ពាយទ្រព្យវប្បធម៌ចាស់កសាង ទុកជាភស្តុតាងឲ្យជាក់ស្តែង
ជាគោលចរឹតប្រាប់ក្មេងៗ ឲ្យស្គាល់កន្លែងដំណែលចាស់។
ឥឡូវបាត់អង្គបង់ទូលតាំង បាត់ប្រាង្គព្រះធាតុមានចំចាស់
ប្រាសាទតូចធំធានីចាស់ សល់ខ្លះខូចខ្លះខ្វះរមណីយ៍។

**ដោយ យី សុធន**

# រាសីប្រចាំខែកក្កដា

**១.ឆ្នាំជូត:** រាសីខែនេះល្អមធ្យម។ ការប្រកបកិច្ចការងារពុំបានទទួលផលល្អឡើយ។ ចំណែកការធ្វើដំណើរត្រូវប្រយ័ត្នបន្តិចទើបបានសុខ។ រីឯការរស់នៅវិញ លោកអ្នកមានភាពប្តូរផ្លាស់ច្រើន ជូនកាលត្រូវរ៉ូវគ្នា ជួនកាលទាស់ទែងគ្នា។

**២.ឆ្នាំឆ្លូវ** រាសីខែនេះល្អមធ្យម។ ការប្រកបរបរជួញដូរមានភាពពុំសូវកាក់កបទេ។ ការធ្វើដំណើរផ្លូវឆ្ងាយប្រព្រឹត្តទៅជាធម្មតា តែត្រូវមានស្មារតីរឹងប៉ឹងកុំជឿសម្តីអ្នកដទៃខ្លាំងពេក។ជីវិតរស់នៅមានការមិនចុះសម្រុងនឹងគ្នាទេ។

**៣.ឆ្នាំខាល** រាសីខែនេះស្រុតចុះ។ ការប្រកបរបររកស៊ីផ្សេងៗទទួលផលជាមធ្យម។ ការធ្វើដំណើរកំសាន្តត្រូវមានការប្រុងប្រយ័ត្នខ្ពស់។រីឯជីវិតរស់នៅក្នុងសង្គមគ្រួសារវិញ មិនសូវមានភាពរុះរាយនិងយល់ចិត្តគ្នាទេ ហើយជួបការរអាក់រអួលផ្លូវចិត្តច្រើន។

**៤.ឆ្នាំថោះ** រាសីខែនេះល្អមធ្យម។ រយៈពេលនេះ កិច្ចការងារណាដែលបំពេញខ្លួនឯងបានគួរខិតខំឲ្យអស់ពីកំលាំងកាយចិត្តនឹងទទួលបានផលល្អ។ ដំណើរចាកចេញក្រៅផ្ទះត្រូវប្រកាន់ចិត្តឲ្យនឹងធឹងមានគេព្យាបាទ តែពុំបានសំរេចទេ។ ចំពោះការរស់នៅមានដំណើរថយក្រោយច្រើន។

**៥.ឆ្នាំរោង** ដួងរាសីខែនេះខ្ពស់ត្រដែត។ បើជាអ្នកប្រកបរបររកស៊ីជួញដូរទទួលជោគជ័យច្រើន អាចប្រមូលបានផលគួរជាទីគាប់ចិត្ត។ ការធ្វើដំណើរជិតឆ្ងាយមានភាពសុខសាន្ត។ រីឯសេចក្តីស្នេហាវិញពុំសូវល្អទេ ច្រើនជួបបញ្ហាក្នុងសង្គមគ្រួសារ។

**៦.ឆ្នាំម្សាញ់** រាសីខែនេះល្អបង្គួរ។ ចំពោះការប្រកបរបរជួញដូរប្រាក់ចំណូលរកបានសមល្មម។ បើការចេញដំណើរផ្លូវឆ្ងាយត្រូវប្រុងប្រយ័ត្នបន្តិចក្រែងជួបគ្រោះថ្នាក់។ រីឯការរស់នៅក្នុងសង្គមគ្រួសារវិញ មានការអធ្យាស្រ័យគ្នាទៅវិញទៅមកបានច្រើន។

**៧.ឆ្នាំមមី** រាសីខែនេះល្អជាមធ្យម។លោកអ្នកប្រកបការងារពុំសូវទទួលផលល្អទេ បើចង់បោះទុនរកស៊ីត្រូវប្រយ័ត្នបន្តិចព្រោះមានការខាតបង់ច្រើន។ បញ្ហាសង្គមគ្រួសារវិញនោះមានដំណើរថយក្រោយបន្តិចនិងចាប់កំហុសគ្នាខ្លះៗ។

**៨.ឆ្នាំមមែ** រាសីខែនេះស្រុតចុះ។ ការជួញដូរផ្សេងៗប្រាក់ចំណូលមានការខ្សត់ខ្សោយបន្តិច ដូច្នេះលោកអ្នកត្រូវតែខិតខំប្រឹងប្រែង។ ចំពោះការធ្វើដំណើរវិញប្រយ័ត្នឧប្បត្តិហេតុយាយី។ ចំណែកការរស់នៅមានការខ្វល់ខ្វាយ ព្រោះតែគិតម្នាក់ឯងច្រើនពេក។

**៩.ឆ្នាំវក** ដួងរាសីខែនេះល្អមធ្យម។ ចំពោះលោកអ្នកប្រកបរបររកស៊ីទទួលបានផលល្អ។ ការធ្វើដំណើរផ្លូវឆ្ងាយពុំសូវមានសុវត្ថិភាពទេ ប្រយ័ត្នឧប្បត្តិហេតុកើតឡើង។ ចំណងអាពាហ៍ពិពាហ៍វិញនោះ មានការប្រែប្រួលមិនទៀងទាត់ទេ ត្រូវចេះអត់ឱនឱ្យគ្នាទៅវិញទៅមក។

**១០.ឆ្នាំរកា** រាសីខែនេះល្អបង្គួរ។ ដំណើរជីវិតប្រកបទៅមុខមិនមានការផ្លាស់ប្តូរទេ។ ចំពោះការប្រកបរបររកស៊ីជួញដូរមានភាពរស់រវើកឡើងវិញ ទទួលបានប្រាក់ចំណេញ សមគួរ។ចំពោះការរស់នៅមានដំណើរជឿនលឿនទៅមុខបង្គួរ។

**១១.ឆ្នាំច** រាសីខែនេះល្អជាមធ្យម។ ការធ្វើដំណើរចាកចេញទៅក្រៅផ្ទះលោកអ្នកមានសុវត្ថិភាពល្អញាតិមិត្តរាប់អាន។ រីឯការរកទទួលទានវិញគឺបានផលជាធម្មតា។ ចំណែកការរស់នៅលោកអ្នកនឹងមានសុភមង្គលល្អក្នុងសង្គមគ្រួសារ។

**១២.ឆ្នាំកុរ** រាសីខែនេះល្អបង្គួរ។ សំរាប់លោកអ្នកប្រកបរបររកស៊ីទទួលបានផលចំណេញគួរសម។ ការធ្វើដំណើរជិតឆ្ងាយគ្មានអ្វីជាឧបសគ្គទេតែត្រូវប្រយ័ត្នបន្តិច ។ចំណែកក្នុងរង្វង់គ្រួសារមានភាពរីកចំរើននិងជឿនលឿនទៅមុខ កំពុងបើកទំព័រជីវិតថ្មីសម្រាប់លោកអ្នកហើយ។

# ទិដ្ឋភាពអ្នកប្រជាធិបតេយ្យខ្មែរ នៅវត្តខេមររង្សី ទីក្រុងសាន់ហូសេ









